Co-funded by the Erasmus+ Programme of the European Union

ចំណងជើងគម្រោង៖ **មណ្ឌលអប់រំសម្រាប់ឧត្តមភាពឆ្មប**

ចំណងជើងឯកសារ៖ គំរូ **SafeMa** សម្រាប់ឧត្តមភាពឆ្មប

អនុប្រធានបទនៃឯកសារ**:** របាយការណ៍

គម្រោងការងារ/ កិច្ចការ/ សមិទ្ធិផល៖ គម្រោងការងារ ១/កិច្ចការ ១.៤/ សមិទ្ធិផល.១.៤

និពន្ធដោយ ៖ **UCN**

UNIVERSITY COLLEGE OF NORTHERN DENMARK

HELLENIC REPUBLIC National and Kapodistrian University of Athens EST. 1837

SCHOOL OF MEDICINE · NKUA MASTER'S COURSE IN GLOBAL HEALTH - DISASTER MEDICINE

ReadLab Research Innovation and Development Lab

# ព័ត៌មាននៃគម្រោង (Project Information)

ពាក្យជាអក្សរកាត់ :  SafeMa
ចំណងជើង : មណ្ឌលអប់រំសម្រាប់ឧត្តមភាពឆ្មប( Education Hubs for Excellence in Midwifery)
លេខនៃកិច្ចព្រមព្រៀង: 598946
កម្មវិធីសហភាពអ៊ឺរ៉ុប: Erasmus +
វេបសាយ គម្រោង: safema-project.eu
រៀបចំដោយ :
ឈ្មោះ : UCN
ដៃគូរបង្កើតកម្មវិធី: UCN
តួនាទី : ដៃគូគម្រោង
កាលបរិច្ឆេទ : សីហា ២០១៩
ជួសមុខអនុមត័ដោយ:
ឈ្មោះ:
ដៃគូ:
តួនាទី:
កាលបរិច្ឆេទ:
ការបដិសេធ៖
ការគាំទ្ររបស់គណៈកម្មការអឺរ៉ុបសម្រាប់ការផលិតការបោះពុម្ពផ្សាយនេះមិនមែនជាការយល់ព្រមលើខ្លឹមសារដែលឆ្លុះបញ្ចាំងពីទស្សនៈរបស់អ្នកនិពន្ធតែប៉ុណ្ណោះទេហើយគណៈកម្មការមិនអាចទទួលខុសត្រូវចំពោះការប្រើប្រាស់ណាមួយដែលអាចត្រូវបានធ្វើឡើងពីព័ត៌មានដែលមាននៅក្នុងនោះទេ។

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

តារាងមាតិកា

១. សេចក្តីផ្តើម (Introduction)....................1
២. ជំពូកទី ១ : ការពិពណ៌នាអំពីវគ្គសិក្សា SafeMa (Chapter 1 Description of the Safema course).........2
២.១. គោលការណ៍ទូទៅវគ្គសិក្សា SafeMa (General principles of the SafeMa course)........................2
២.២ គន្លឹះការពិចារណាសម្រាប់ WP ១.៥ ទាក់ទងនឹងសិទ្ធិមនុស្ស (Key Considerations for WP 1.5 regarding a human rights-based approach)....................3
២.៣ វិធីសាស្រ្ត (Methodology)....................3
២.៣.១ ទស្សនៈវិជ្ជារួម (Overall philosophical approach)....................3
២.៣.២ ទ្រឹស្តីដើម្បីគាំទ្រដល់ដំណើរការអភិវឌ្ឍន៍ (Theoretical framework to support development rocesses)....................4
២.៣.៣ គន្លឹះពិចារណាសម្រាប់ WP ១.៥ (Key Considerations for WP 1.5)....................4
២.៤ ក្រេឌីត (Credit points)....................5
២.៤.១ គន្លឹះពិចារណាសម្រាប់ WP ១.៥ (Key Considerations for WP 1.5)....................5
២.៥ ឧបករណ៍ (Tools)....................5
២.៥.១ MOOCs (Massive Open Online Courses)....................5
២.៥.២ បាឋកថា (Lectures)....................6
២.៥.៣ ការរៀបចំ (Preparation)....................6
២.៥.៤ ការងារជាក្រុម (Group work)....................6
២.៥.៥ ថ្ងៃសិក្សា (Study days)....................6
២.៥.៦ កិច្ចការត្រូវបំពេញ (Assignment)....................6
២.៥.៧ ការប្រឡង/ ការធ្វើតេស្ត (Exams/tests)....................6
២.៥.៨ គ្រឿងបរិក្ខារ (Facilities)....................7
២.៥.៩ គន្លឹះពិចារណាសម្រាប់ WP ១.៥ (Key Considerations for WP 1.5)....................7
៣. ប្លង់ នៃម៉ូឌុលទាំង ៨ (Outline of the 8 modules )....................7
៣.១ បទបង្ហាញម៉ូឌុលទាំង ៨ របស់គម្រោង SafeMa (Presentation of the 8 SafeMa modules)........9
៣.២ ម៉ូឌុលទី ១៖ ការធ្វើឲ្យប្រសើឡើងនូវជំនាញគ្លីនិកឆ្មប-ការលើកកម្ពស់ឲ្យមានការឈឺពោះសម្រាលកូនធម្មតា (Module 1: Advanced clinical skills in midwifery – promoting normal labor)....................9
៣.២.១ មាតិការ (Content)....................9
៣.២.២ លទ្ធផលនៃការសិក្សា (Learning outcomes)....................9
៣.២.៣ សមត្ថភាពនិស្សិត (Competencies)....................9
៣.២.៤ ចំណេះដឹងនិស្សិត (Knowledge )....................9
៣.២.៥ ជំនាញ (Skills)....................10
៣.២.៦ ប្លង់នៃម៉ូឌុល (Outline of the module)....................10
៣.២.៧ គន្លឹះពិចារណាលើផែនការ WP ១.៥ របស់គម្រោងឧត្តមភាព (Considerations for WP1.5 Excellency plans)....................10
៣.៣ ម៉ូឌុលទី ២៖ ការអនុវត្តជំនាញគ្លីនិកកម្រិតខ្ពស់ឆ្មបទី២ - ការតាមដានគភ៌និងសុវត្ថិភាពម្តាយ (Module 2: Advanced clinical skills in midwifery II – Fetal monitoring and patient safety)........11

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

៣.៣.១ មាតិការ (Content) ........ 11
៣.៣.២ លទ្ធផលនៃការសិក្សា (Learning outcomes) ........ 11
៣.៣.៤ ចំណេះដឹងនិស្សិត (Knowledge)........ 11
៣.៣.៥ ជំនាញ (Skills)........ 11
៣.៣.៦ ប្លង់នៃម៉ូឌុល (Outline of the module) ........ 12
៣.៣.៧ គន្លឹះពិចារណា WP.១.៥ (Key Considerations for WP 1.5) ........ 12

**៣.៤ ម៉ូឌុលទី ៣៖ ការអនុវត្តគ្លីនិកកម្រិតខ្ពស់ ឆ្មបទី ៣ ការសង្គ្រោះបន្ទាន់ម្តាយនិងទារក (MODULE 3: Advanced clinical skills in midwifery III – Obstetric emergencies)........ 12**
៣.៤.១ មាតិការ (Content)........ 12
៣.៤.២ លទ្ធផលនៃការសិក្សា (Learning outcomes) ........ 12
៣.៤.៣ សមត្ថភាពនិស្សិត (Competencies) ........ 12
៣.៤.៤ ចំណេះដឹងនិស្សិត ( Knowledge) ........ 13
៣.៤.៥ ជំនាញ (Skills ) ........ 13
៣.៤.៦ ប្លង់នៃម៉ូឌុល (Outline of the module) ........ 13
៣.៤.៧ គន្លឹះពិចារណា WP ១.៥ ឧត្តមភាពផែនការ (Considerations for WP1.5 Excellency plans) 14

**៣.៥ ម៉ូឌុលទី ៤៖ ការលើកកម្ពស់សុខភាពក្រោយសម្រាលក្នុងការគ្រប់គ្រងរបស់ឆ្មប (MODULE 4: Post-partum health promotion within midwifery) ........ 14**
៣.៥.១ មាតិការ (Content)........ 14
៣.៥.២ លទ្ធផលនៃការសិក្សា (Learning outcomes) ........ 14
៣.៥.៤ ចំណេះដឹងនិស្សិត (Knowledge ) ........ 14
៣.៥.៥ ជំនាញ (Skills ) ........ 15
៣.៥.៦ ប្លង់នៃម៉ូឌុល (Outline of the module)........ 15
៣.៥.៧ គន្លឹះពិចារណា WP១.៥ ផែនការឧត្តមភាព (Considerations for WP1.5 Excellency plans) 16

**៣.៦ ម៉ូឌុលទី ៥៖ វិធីសាស្ត្រស្រាវជ្រាវសុខភាព (MODULE 5: Methods in health research )........ 16**
៣.៦.១ មាតិការ (Content ) ........ 16
៣.៦.២ លទ្ធផលនៃការសិក្សា (Learning outcomes) ........ 16
៣.៦.៤ ចំណេះដឹង (Knowledge )........ 16
៣.៦.៥ ជំនាញ (Skills)........ 16
៣.៦.៦ ប្លង់នៃម៉ូឌុល (Outline of the module)........ 17
៣.៦.៧ គន្លឹះពិចារណា WP ១.៥ ផែនការឧត្តមភាព (Considerations for WP1.5 Excellency plans) 17

**៣.៧ ម៉ូឌុលទី ៦: ភាពជាគ្រូដឹកនាំកម្មសិក្សាគ្លីនិក (MODULE 6: Clinical preceptorship )........ 17**
៣.៧.១ មាតិការ (Content) ........ 17
៣.៧.២ លទ្ធផលសិក្សា (Learning outcomes)........ 17
៣.៧.៣ សមត្ថភាព (Competencies ) ........ 17
៣.៧.៤ ចំណេះដឹង (Knowledge)........ 17
៣.៧.៥ ជំនាញ (Skills) ........ 18
៣.៧.៦ ប្លង់នៃម៉ូឌុល (Outline of the module)........ 18
៣.៧.៧ គន្លឹះពិចារណា WP ១.៥ ផែនការឧត្តមភាព (Considerations for WP1.5 Excellency plans) 18

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

៣.៨ ម៉ូឌុលទី ៧៖ សិទ្ធិមនុស្ស (MODULE 7: Human rights ) .......... **18**
៣.៨.១ មាតិការ (Content) .......... 18
៣.៨.២ លទ្ធផលសិក្សា (Learning outcomes).......... 19
៣.៨.៣ សមត្ថភាព ( Competencies) .......... 19
៣.៨.៤ ចំណេះដឹង ( Knowledge) .......... 19
៣.៨.៥ ជំនាញ (Skills) .......... 19
៣.៨.៦ ប្លង់នៃម៉ូឌុល (Outline of the module ).......... 19
៣.៨.៧ គន្លឹះពិចារណា WP១.៥ ផែនការឧត្តមភាព(Considerations for WP1.5 Excellency plans) 20

៣.៩.ម៉ូឌុលទី ៨៖ ការអនុវត្តជាក់ស្តែងនិងការផ្សព្វផ្សាយរបស់ឆ្មប (MODULE 8: Evidence based midwifery) .......... **20**
៣.៩.១ មាតិការ (Content ) .......... 20
៣.៩.២ លទ្ធផលសិក្សា (Learning outcomes) .......... 20
៣.៩.៣ សមត្ថភាព (Competencies ) .......... 20
៣.៩.៥. ជំនាញ (Skills).......... 20
៣.៩.៧ គន្លឹះពិចារណា WP ១.៥ ឧត្តមភាពផែនការ (Considerations for WP1.5 Excellency plans) 21
៣.១០ ការចុះកម្មសិក្សាគ្លីនិក (Facilitated internship) .......... 21
៣.១០.១ គន្លឹះពិចារណា WP ១.៥ សម្រាប់ផែនការឧត្តមភាព (Key Considerations for WP 1.5 Excellence plans).......... 23

៤. ជំពូកទី ២ ការស្រាវជ្រាវ SafeMa (Chapter 2 Safema research).......... 23

៤.២ ការរៀបចំប្រតិបត្តិ (The setting of implementation) .......... **24**

៤.៣ គោលការណ៍និងសារៈសំខាន់នៃការគាំទ្រការអនុវត្តជាក់ស្តែងនិងការផ្សព្វផ្សាយ (Principles and importance of supporting an Evidence Based Practice ) .......... **24**
៤.៤ គោលដៅនិងការយល់ដឹងអំពីទម្រង់ព័ត៌មានដើម្បីគាំទ្រដល់ការយល់ដឹងអំពីការស្រាវជ្រាវ (Goals and understandings of the Information Competency Profile to support research awareness**............** 38

៤.៥ ការប្រមូលការស្រាវជ្រាវ (Collection of research).......... **26**

៤.៦ គន្លឹះពិចារណាសម្រាប់ WP ១.៥ (Key Considerations for WP 1.5).......... **28**

៥. ជំពូកទី ៣ ការណែនាំអំពីវិជ្ជាជីវៈ (Chapter 3 Career guidance).......... 28

៥.១ ការណែនាំវិជ្ជាជីវៈក្នុង SafeMa (SafeMa career guidance).......... **28**
៥.១.១ ព័ត៌មានអាជីព (Career information) .......... 28
៥.១.២ ការអប់រំអាជីព (Career education) .......... 28
៥.១.៣ ការប្រឹក្សាយោបល់អាជីព (Career counseling) .......... 29
៥.១.៤ ការប្រឹក្សាការងារ (Employment counseling) .......... 29
៥.១.៥ ការរកការងារធ្វើ (Job placement ) .......... 29

៥.២ គន្លឹះពិចារណាសម្រាប់ WP ១.៥ (Key Considerations for WP 1.5).......... **29**

៦. ជំពូកទី ៤ ចីរភាពគម្រោង (Chapter 4 Project sustainability).......... 29

៦.១ គន្លឹះពិចារណាសម្រាប់ WP ១.៥ (Key Considerations for WP 1.5) .......... **31**

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

៦.២ សេចក្តីសង្ខេបប្រតិបត្តិ (Executive summary) ... 31
៦.២.១ ចំណងជើងសម្រាប់ម៉ូឌុលទាំង ៨ (Headlines for the 8 modules) ... 31
៧. ឯកសារយោង (References) ... 33

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

តួលេខ

រូបភាពទី ១: ឧទាហរណ៍អំពីគោលការណ៍គ្រឹះនៃការបង្រៀនជំរុញការរៀនអនុវត្តការឆ្លុះបញ្ចាំង
(ការបកប្រែរបស់យើង)(៧) ....................................................................................5
រូបភាពទី ២: ឧទាហរណ៍ប្រសិនបើសំណួរសំខាន់នៅក្នុងរង្វង់ឆ្លុះបញ្ចាំង
(ការបកប្រែរបស់យើង) (១២)....................................................................................33
រូបភាពទី ៣: បង្ហាញពីធាតុសំខាន់ៗនៃសមត្ថភាពព័ត៌មាន
(ការបកប្រែរបស់យើង) (១៣)....................................................................................38
រូបភាពទី ៤: រូបភាពបង្ហាញពីធាតុសំខាន់ៗនៃឧបករណ៍UCN DOSIS
(ការបកប្រែរបស់យើង) (១១)....................................................................................40

រូបភាព

រូបភាពទី ១: រូបភាពពីការធ្វើទស្សនកិច្ចសិក្សានៅដាណឺម៉ាកៈ ក្រុមប្រឹក្សាភិបាលដែលរួមបញ្ចូលជាមួយនឹងការផ្តល់យោបល់របស់ដៃគូ SafeMa សម្រាប់មាតិកានៃម៉ូឌុល...........11

The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

## ១. សេចក្តីផ្តើម (Introduction)

ជាផ្នែកមួយនៃគម្រោង SafeMa របាយការណ៍នេះ ត្រូវបានពិពណ៌នា ជាកញ្ចប់ការងារទី ១ កិច្ចការទី ៤ (WP ១.៤) នៅក្នុងការពិពណ៌នាគម្រោងលម្អិត (១) ។ របាយការណ៍នេះ៖ SafeMa ។ គំរូសម្រាប់ឧត្តមភាពឆ្មបនេះមានគោលបំណងបង្ហាញពីស្តង់ដារច្បាស់លាស់សម្រាប់វគ្គសិក្សា SafeMa ដែលនឹងត្រូវបង្កើតឡើងនៅក្នុងប្រទេសជាដៃគូ។ ទោះបីជាការផ្តោតសំខាន់នៃរបាយការណ៍នេះមិនផ្តោតលើការអភិវឌ្ឍខ្លឹមសារ (Hubs)
ក៏ដោយក៏និយាមទាំងនេះនឹងចូលរួមចំណែកដល់ការអភិវឌ្ឍកម្មវិធីសិក្សា និងមណ្ឌល (Hubs )នៅក្នុង WP ២ (១) ។

របាយការណ៍នេះនឹងផ្អែកលើចំណេះដឹងដ៏មានតម្លៃដែលប្រមូលបានក្នុងសកម្មភាពនិងកិច្ចការដែលបានបំពេញទាក់ទងនឹងWP.១។ របាយការណ៍នេះក៏រួមបញ្ចូលទាំងអក្សរសាស្ត្រនិងទ្រឹស្តី ផងដែរ។

**របាយការណ៍៖** ការសិក្សានិងការស្រាវជ្រាវឧត្តមភាពក្នុងការអប់រំឆ្មបនិងស្រាវជ្រាវ (WP .១.១) ត្រូវបានបង្កើតឡើងជា មគ្គុទេស៍ដើម្បីឧត្តមភាពក្នុងការអប់រំ ស្រាវជ្រាវនិងអនុវត្តទៅលើឆ្មប (២)។ តាមរយៈការពិនិត្យដ៏លម្អិតទៅលើនិយាម វិធីសាស្ត្រ និងការអនុវត្តន៍បែបអន្តរជាតិដែលល្អបំផុតវាអាចផ្តល់ឱ្យយើងនូវចំណេះដឹងអំពីឧត្តមភាពឆ្មប។
ដូច្នេះរបាយការណ៍នេះនឹងរៀបរាប់ពីមូលដ្ឋានគ្រឹះសម្រាប់ការវិភាគចំនុចខ្វះខាតនៃ SafeMa (WP ១.២) ដើម្បីវាយតម្លៃពីនិយាមនៅក្នុងសាកលវិទ្យាល័យនៃប្រទេសជាដៃគូក្នុងស្ថានភាពបច្ចុប្បន្ន។

ចំណេះដឹងទាក់ទងនឹងនិយាមអន្តរជាតិ ការអនុវត្តន៍ដ៏ល្អប្រសើរ និងវិធីសាស្ត្រទាំងនេះនឹងត្រូវបានយកធ្វើជាឯកសារយោងនៅក្នុងរបាយការណ៍នេះផងដែរ
ដើម្បីគោរពតាមនិយាមល្អបំផុតនៅក្នុងវិស័យអប់រំឆ្មប ការស្រាវជ្រាវ និងការអនុវត្តនៅក្នុងការវគ្គសិក្សា។

WP១.២ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងចំណេះដឹងទាក់ទងនឹងការសិក្សា ហើយគោលបំណងនៃ WP ១.២ គឺដើម្បីពង្រឹងការយល់ដឹងរបស់យើងអំពីកាលៈទេសៈបច្ចុប្បន្ននៃការអប់រំផ្នែកឆ្មបក្នុងការរៀបចំប្រទេសជាដៃគូ (៣) ។ ចំណេះដឹងនេះត្រូវបានរួមបញ្ចូលនៅក្នុងការអភិវឌ្ឍដែលមាននៅក្នុងរបាយការណ៍នេះ ដើម្បីគាំទ្រដល់ទស្សនវិស័យដែលផ្អែកទៅលើតម្រូវការនិងការកែតម្រូវតាមបរិបទទៅក្នុងវគ្គសិក្សារបស់ SafeMa ។

ក្នុងកំឡុងពេលពង្រឹងសមត្ថភាព រួមមានដំណើរទស្សនកិច្ចសិក្សានៅតាមសាកលវិទ្យាល័យនានានៃសហភាពអឺរ៉ុប (WP ១.៣) ដៃគូប្រតិបត្តិបានជួបប្រទះវគ្គសិក្សាដែលគាំទ្រដល់ការធ្វើសមាហរណកម្មក្នុងការអនុវត្តទ្រឹស្តីនៃការសិក្សាគ្លីនិក ។ ដោយហេតុនេះពួកគេបានស្គាល់ច្បាស់ពីការទាក់ទងនឹងគោលការណ៍រៀនបច្ចេកទេសនិងមុខវិជ្ជាដែលបានរួមបញ្ចូលនៅក្នុងការអភិវឌ្ឍវគ្គសិក្សា SafeMa ។ ការរៀបចំនៃការពង្រឹងសមត្ថភាពនេះត្រូវបានផ្អែកទៅលើការទទួលស្គាល់គ្នាទៅវិញទៅមកនៃទស្សនៈវិស័យ ដែលអនុញ្ញាតឱ្យមានការពិភាក្សា ការឆ្លុះបញ្ចាំងពីចំណេះដឹងដែលទទួលបាន និងការចែករំលែកនូវអ្វីដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍។
ដូច្នេះលទ្ធផលដែលទទួលបានក្នុងស្ថានភាពបច្ចុប្បន្ននេះត្រូវបានគេមើលឃើញថាអាចមានលទ្ធភាពក្នុងការព្រមព្រៀងគ្នាលើរចនាសម្ព័ន័ដ៏ទូលំទូលាយ
ប៉ុន្តែយើងសង្ឃឹមថារចនាសម្ព័ននេះអាចផ្ទេរនិងមានភាពស្រដៀងគ្នាក្នុងវគ្គសិក្សាទាំងអស់។
ដូច្នេះហើយវាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងរបាយការណ៍ព័ត៍មាននេះក៏ដូចជានៅក្នុងកិច្ចការផ្សេងទៀតនៅក្នុងWP ១ ។

គោលបំណងនៃរបាយការណ៍៖

របាយការណ៍នេះមានគោលបំណងដើម្បីបង្កើតទិដ្ឋភាពទូទៅនៃវគ្គបណ្តុះបណ្តាល ទស្សនៈវិជ្ជាគរុកោសល្យ និងវិធីសាស្ត្រដោយផ្អែកលើគម្រោង SafeMa (១) ។


The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

បន្ទាប់ពីនេះសាកលវិទ្យាល័យនីមួយៗនឹងបង្កើតយុទ្ធសាស្ត្រផ្ទាល់ខ្លួនសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព ព្រោះពួកគេនឹងនៅតែបន្តការងាររបស់គម្រោង SafeMa (WP ១.៥) (១) ។

## ២. ជំពូកទី ១ : ការពិពណ៌នាអំពីវគ្គសិក្សា SafeMa (Chapter 1 Description of the Safema course)

### ២.១. គោលការណ៍ទូទៅវគ្គសិក្សា SafeMa (General principles of the SafeMa course)

គោលការណ៍ទូទៅវគ្គសិក្សា SafeMa ត្រូវបានបង្កើតឡើងដោយផ្អែកលើសិទ្ធិមនុស្ស។ វាបានពិពណ៌នាក្នុង WP ១.១ដែល វិធីសាស្ត្របែបនេះ ដើម្បីគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចិរភាព (១.២)។

វគ្គសិក្សារបស់ SafeMa ត្រូវបានណែនាំឲ្យគោរព សិទ្ធិមនុស្ស នៅពេលកំណត់វត្ថុបំណងនៃវគ្គសិក្សាដូចជា ជួយលុបបំបាត់រាល់ទម្រង់នៃការរើសអើង (២) ។ អង្គការសុខភាពពិភពលោកបានសង្កត់ធ្ងន់បន្ថែមទៀតឲ្យ យកចិត្តទុកដាក់ខ្ពស់ទៅលើសិទ្ធិមនុស្សដែលជាសមាសធាតុ ដ៏សំខាន់នៃការថែទាំប្រកបដោយគុណភាពដោយអាចការពារនិងលុបបំបាត់ការការមិនគោរពក្នុងកំឡុងពេល សម្រាលកូននិងក្នុងកម្មវិធីអប់រំ (២) ។

បន្ថែមពីសិទ្ធិមនុស្ស អង្គការសុខភាពពិភពលោកក៏បានផ្តល់អនុសាសន៍បន្ថែម លើការថែទាំស្ត្រី ក្នុងពេលសម្រាលសម្រាប់កំណើតរសតាំងពីឆ្នាំ ២០១៨ បង្ហាញពី ការយកចិត្តទុកដាក់លើស្ត្រី។ នេះដើម្បីបង្កើនប្រសិទ្ធភាព ការងារនិងការសម្រាលកូន ចំពោះស្ត្រីនិងទារកតាមរយៈវិធីសាស្ត្ររួម (៤) ។ វិធីសាស្ត្ររួមតម្រូវឱ្យមានគំរូសង្គមនៃការសម្រាលកូន ជាជាងផ្តោតសំខាន់ទៅលើគុណតម្លៃ និងជំនឿដែលគាំទ្រតែគំរូនៃការថែរក្សាតាមបែបជីវសាស្ត្រ (៥) ។

ការរៀបចំផែនការនិងការប្រតិបត្តិវគ្គសិក្សារបស់ SafeMa គឺផ្អែកលើទស្សនៈវិស័យកម្មសិក្សាស្របតាមការយល់ដឹងនិងការបកស្រាយបែបវេជ្ជសាស្ត្រដោយផ្អែកលើភស្តុតាង(EBM)។ ការបកស្រាយនេះក៏ រួមបញ្ចូលទាំងបទពិសោធន៍ ជំនាញ សុខភាពនិងចំណង់ចំណូលចិត្តរបស់អ្នកជំងឺក្នុងការសម្រេចចិត្តផ្អែកលើភស្តុតាង(៥.៦)។ ក្នុងកំឡុងពេលរៀបចំកម្មវិធី WP ១.៣ ដៃគូនៅក្នុងគម្រោង SafeMa បានទទួលស្គាល់ពីការពាក់ព័ន្ធអំពីក្រមសីលធម៌និងទស្សនៈគុណតម្លៃ និងបទពិសោធន៍របស់ស្ត្រីដែលជាផ្នែកសំខាន់មួយនៃវគ្គសិក្សា SafeMa ។ ពួកគេក៏បានរកឃើញថាតម្រូវការសំខាន់មួយនៅក្នុងបរិបទរបស់ពួកគេ។

នៅក្នុង WP ១.១ ក្របខ័ណ្ឌរបស់អង្គការសហប្រជាជាតិ (UN) ត្រូវបានពិពណ៌នាថាមានភាពសមរម្យអំពីម្រាប់ការណែនាំវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស (២) ។ UN បានកំណត់ធាតុស្នូលគឺសិទ្ធិមនុស្សក្នុងគោលដៅ ដំណើរការ និងលទ្ធផល (២) ។

យោងតាម WP ១.១ ការអភិវឌ្ឍកម្មវិធីសិក្សារបស់វគ្គសិក្សា SafeMa ចាំបាច់ត្រូវយកសិទ្ធិមនុស្សជាស្នូលដោយធ្វើសមាហរណកម្ម និងគាំទ្រសិទ្ធមនុស្សជាប្រព័ន្ធ (២) ។

និស្សិតសិក្សាវគ្គសិក្សា SafeMa នឹងទទួលបានចំណេះដឹងអំពីសារៈសំខាន់នៃការគោរពសិទ្ធិមនុស្សនិងរៀនអំពីការតស៊ូមតិសម្រាប់ស្ត្រីដើម្បីធ្វើការថែទាំសុខភាពរបស់ស្ត្រីត្រូវបានគោរព ។

និស្សិតនឹងទទួលបាននូវចំណេះដឹងនិងជំនាញដើម្បីផ្តល់ការថែទាំសុខភាពទាន់ពេលវេលានិងសមរម្យ (២) ។ ដូច្នេះសិទ្ធិមនុស្សនិងក្រមសីលធម៌ត្រូវបានរៀបចំជាប្រធានបទចំបងនៅក្នុងវគ្គសិក្សា SafeMa ដើម្បីបង្កើនចំណេះដឹងដល់សិស្សអំពីសមត្ថភាពស្នូលនៃការអនុវត្តន៍វិជ្ជាជីវៈនិងមានក្រមសីលធម៌ នៅក្នុងការអនុវត្តវិជ្ជាជីវៈរបស់ខ្លួន។

ដើម្បីគោរពគោលការណ៍ធាតុស្នូល ដូចជាការមិនរើសអើង និងគណនេយ្យភាពគួរដាក់បញ្ចូលគ្រប់ដំណាក់កាលនៃការធ្វើផែនការនិងការប្រតិបត្តិនៅក្នុងវគ្គសិក្សា SafeMa (២)។ ចំណេះដឹងអំពីវិធីគាំទ្រនិងធានាសិទ្ធរបស់អតិថិជនក្នុងការសម្រេចចិត្តចូលរួមដោយសេរី គ្មានការរើសអើង និងមានអត្ថន័យក្នុងការសម្រេចចិត្ត ។ នៅក្នុង WP ១.១ គឺមានភាពច្បាស់លាស់ដើម្បីគាំទ្រចំណេះដឹង និងជំនាញដល់និស្សិត ដើម្បីឲ្យពួកគេផ្តល់ព័ត៌មានច្បាស់ និងដំណើរការច្បាស់លាស់ ។



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ដូច្នេះវគ្គសិក្សារបស់ SafeMa នឹងបញ្ចូលចំណេះដឹងពីជំនាញគ្លីនិកនិង ភស្តុតាងដើម្បីអនុវត្តបានប្រសើ និងការប្រាស្រ័យទាក់ទង គាំទ្រដល់ការសម្រេចចិត្តក្នុងពេលអនុវត្តគ្លីនិក។

យោងតាមធាតុស្នូលចុងក្រោយ ផ្អែកលើសិទ្ធិមនុស្ស និស្សិតត្រូវមានចំណេះដឹងទាក់ទងនឹងការគោរព។ ពួកគេមានកាតព្វកិច្ចក្នុងការធានាថា អាចអនុវត្តប្រកបដោយការគោរព និងត្រូវគាំទ្រការអនុវត្តដែលមិនជ្រៀតជ្រែកដោយផ្ទាល់ឬដោយប្រយោលជាមួយនឹងសិទ្ធិទទួលបានសុខភាព។ កាតព្វកិច្ចទាំនេះ មានសារៈសំខាន់ជាពិសេសទាក់ទងនឹងកាតព្វកិច្ចការពារអតិថិជនពីហានិភ័យនៃអំពើហឹង្សាលើផ្នែកសម្ភព (២) ។

## ២.២ គន្លឹះការពិចារណាសម្រាប់ WP ១.៥ ទាក់ទងនឹងសិទ្ធិមនុស្ស (Key Considerations for WP 1.5 regarding a human rights-based approach)

ដៃគូទាំងអស់របស់ SafeMa ត្រូវតែប្តេជ្ញាចិត្តក្នុងការធ្វើសមាហរណកម្មនិងគាំទ្រវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សនៅគ្រប់ដំណាក់កាលនៃការធ្វើផែនការនិងការប្រតិបត្តិនៃគម្រោង SafeMa។ ការពិចារណាបញ្ហានេះស្ថិតនៅផ្នែកមួយនៃគម្រោង WP១.៥ សម្រាប់ឧត្តមភាព។

## ២.៣ វិធីសាស្ត្រ (Methodology)

វិធីសាស្ត្រនេះត្រូវបានពិពណ៌នាទាំង ទស្សនៈវិជ្ជាទាក់ទងនឹងការអប់រំ និងការរៀនសូត្រសម្រាប់និស្សិតឆ្មប ក៏ដូចជាក្របខ័ណ្ឌទ្រឹស្តីសម្រាប់ការប្រមូលទិន្នន័យសំខាន់ៗក្នុងពេលប្រតិបត្តិ WP១.៣ដើម្បីភាពងាយស្រួលក្នុងវគ្គសិក្សា SafeMa ។ ក្របខ័ណ្ឌទ្រឹស្តីនេះក៏ត្រូវបានប្រើនៅក្នុងដំណើរការនៃការអភិវឌ្ឍវគ្គសិក្សា SafeMa ផងដែរ។

### ២.៣.១ ទស្សនៈវិជ្ជារួម (Overall philosophical approach)

ទស្សនៈវិជ្ជារួមនៃវគ្គសិក្សា SafeMa ត្រូវបានផុំផុសគំនិតដោយទស្សនៈវិជ្ជានៃការអនុវត្តតាមរយៈការឆ្លុះបញ្ចាំង (Reflective Practice Learning) (៧) ។ តាមវិធីសាមញ្ញ ការរៀនតាមបែបអនុវត្តជាក់ស្តែងអាចត្រូវបានពិពណ៌នាពីការឆ្លុះបញ្ចាំងលើការ នៅក្នុងដោយភ្ជាប់ការអនុវត្ត។
ដូច្នេះការឆ្លុះបញ្ចាំងត្រូវបានដាក់ជាផ្នែកមួយដ៏សំខាន់នៃដំណើរការក្នុងការរៀននិងមានទំនាក់ទំនងរវាងទ្រឹស្តីនិងការអនុវត្ត (៧)។ នេះតម្រូវឱ្យមានការចូលរួមពីនិស្សិតហើយប្រកបដោយការគិតនិងសមត្ថភាពសំខាន់ៗរបស់និស្សិតក្នុងការសម្រេចចិត្តធ្វើ។
វាមិនមែនជាបញ្ហាទេប្រសិនបើវាស្ថិតក្នុងស្ថានភាពអប់រំ ឬការអនុវត្ត ប៉ុន្តែវាអាចជម្រុញឱ្យនិស្សិតរៀនពីរបៀបជជែកពិភាក្សា ក្នុងការជ្រើសរើសវិជ្ជាជីវៈរបស់ពួកគេ(៧) ។
ទស្សនៈវិជ្ជានេះ ជាមូលដ្ឋានគ្រឹះមាននៅក្នុងសៀវភៅ ដែលបានបង្ហាញក្នុងរូបភាពទី ១ ។



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

Co-funded by the Erasmus+ Programme of the European Union




**រូបភាពទី ១៖** ការបង្ហាញអំពីគោលការណ៍គ្រឹះនៃការបង្រៀន លើការលើកកម្ពស់ការរៀនបែបការឆ្លុះបញ្ចាំងតាមរយៈការអនុវត្ត (៧)។

ទស្សនៈវិជ្ជារួម ផ្តោតលើការឆ្លុះបញ្ចាំង និងការចូលរួមរបស់និស្សិតដែលជា ធាតុស្នូល នៃវគ្គសិក្សា SafeMa ។ ដូច្នោះចំពោះ WP ១.១ ការអនុវត្តទៅតាមនិយាមស្តង់ដាល្អបំផុតដែលបានពិពណ៌នាជំនឿ និងគុណតម្លៃរបស់កម្មវិធីអំពីការបង្រៀននិងការរៀនអំពីការថែទាំរបស់ឆ្មបសំខាន់ (២)។

២.៣.២.ទ្រឹស្តីដើម្បីគាំទ្រដល់ដំណើរការអភិវឌ្ឍន៍ (Theoretical framework to support development processes)

បន្ថែមពីលើការប្រមូលព័ត៌មានក្នុងកំឡុងពេលអនុវត្ត WP ១.៣ ឯកសារព័ត៌មានមួយត្រូវបានបង្កើតឡើង ដើម្បីបញ្ជាក់ពីគំរូការនិងគំនិតដៃគូរបស់យើងថែមទៀតក៏ដូចជាការសាកល្បងបទពិសោធន៍និងការយល់ឃើញរបស់វគ្គដែលបានបង្ហាញ ។ ឯកសារព័ត៌មានត្រូវបានបង្កើតឡើងដោយផ្អែកលើទ្រឹស្តី នៃគំរូនៃទំនាក់ទំនងមាន៦ ប្រភេទ។ ប្រភេទទាំងនេះគឺពឹងផ្អែក គ្នាទៅវិញទៅមក ហេតុដូច្នេះហើយវាពិតជាសំខាន់សម្រាប់ពិចារណាក្នុងអំឡុងពេលរៀបចំធ្វើផែនការនៃដំណើរការបង្រៀន (៨) ។ នៅក្នុងការបកប្រែរបស់យើងពីភាសាដាណឺម៉ាកទៅជាភាសាអង់គ្លេស, ប្រាំមួយប្រភេទនៃគំរូទំនាក់ទំនងសម្រាប់បង្រៀនមាន៖ លក្ខខណ្ឌសម្រាប់ការសិក្សា, កត្តាបរិបទ, គោលបំណង, មាតិកា, ដំណើរការសិក្សា និង ការវាយតម្លៃ(៨) ។ វាពាក់ព័ន្ធជាពិសេសនៅពេលវាផ្តោតលើកត្តាទំនាក់ទំនងនិងបរិបទដែលក្នុងនោះសកម្មភាពរៀនត្រូវបានកើតឡើង (៨) ។ ក្នុងកំឡុងពេលដៃគូរប្រតិបត្តិ WP ១.៣បង្កើតបានជាបរិបទនិងបង្ហាញទំនាក់ទំនងដែលពួកយើងមិនធ្លាប់ស្គាល់ពីមុនមក។

ដូច្នេះការសម្របសម្រួល ទ្រឹស្តីនេះនឹងបានគាំទ្រ ការឆ្លុះបញ្ចាំងដើម្បីប្រមូលទិន្នន័យអំពីប្រាំមួយប្រភេទ។

២.៣.៣ គន្លឹះពិចារណាសម្រាប់ WP ១.៥ របស់គម្រោងឧត្តមភាព (Considerations for WP1.5 Excellency plans)



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ទស្សនៈវិជ្ជារួមនៃវគ្គសិក្សា SafeMa ត្រូវបានបំផុសគំនិត ទស្សនៈវិជ្ជាតាមរយៈការអនុវត្ត ។ វិធីសាស្ត្រនេះនឹងណែនាំពីការអភិវឌ្ឍ ដោយ SafeMa WP២។ ដៃគូទាំងអស់ត្រូវតែប្តេជ្ញាថាមានគោលគំនិតការរៀនដោយអនុវត្ត ដែលជាមូលដ្ឋានសម្រាប់ការប្រតិបត្តិក្នុងវគ្គសិក្សាហើយពិភាក្សា ទាក់ទងនឹងបញ្ហានេះមាននៅ WP១.៥ នៃផែនកាសម្រាប់ឧត្តមភាព។

## ២.៤ ក្រេឌីត (Credit points)

ក្នុងបរិបទ SafeMa ពាក្យ "ECTS"( European Credit Transfer System)= ប្រព័ន្ធផ្ទេរក្រេឌីតរបស់អឺរ៉ុបត្រូវបានប្រើក្នុងគម្រោង។ ប្រព័ន្ធអប់រំរបស់អឺរ៉ុប ឆ្នាំសិក្សាត្រូវបានកំណត់ 60 ECTS ។ 1,5 ECTS សិក្សាពេញមួយសប្តាហ៍៥ថ្ងៃ ហើយក្នុង១ថ្ងៃពេញពេលស្មើ២.៣០ម៉ោង ១ឆមាសមាន ៣០ ECTS។

ក្នុងគំរោង SafeMa យើងបំលែង ECTS អោយទៅជាក្រេឌីត ប៉ុន្តែយើងមិនទាន់ទទួលបានជោគជ័យក្នុងការឲ្យយល់ ដើម្បីកំណត់ន័យនៃវគ្គសិក្សា SafeMa នៅឡើយ។ រហូតដល់ពេលនេះដៃគូទាំងអស់បានការកំណត់ន័យ និង ការបកប្រែត្រូវបានបញ្ចប់នឹងដាក់ជូនសគមអឺរ៉ុប។ the SafeMa postgraduate course ១ឆមាសមាន៤ម៉ូឌុល ហើយក្នុង១ខែមាន១ម៉ូឌុល ដូច្នេះក្នុង៤ខែមាន ៤ ម៉ូឌុល និងក្នុង១ឆមាសមានកម្មសិក្សាគ្លីនិកចំនួន២ខែ។ មួយម៉ូឌុលមាន ៥ ECTS ហើយកម្មសិក្សាគ្លីនិក ១០ ECTS រយៈពេល ២ ខែ ។

### ២.៤.១ គន្លឹះពិចារណាសម្រាប់ **WP** ១.៥ របស់គម្រោងឧត្តមភាព (Considerations for WP1.5 Excellency plans)

ដៃគូអាស៊ានត្រូវបានគេរំពឹងថានឹងឆ្លើយតបនៅក្នុងផែនការឧត្តមភាពរៀងៗខ្លួនដើម្បីជួយដល់ការសម្រេចចិត្តនៃការបកប្រែ ECTS ទៅជាចំណុចក្រេឌីតអាស៊ាន។

## ២.៥ ឧបករណ៍ (Tools)

ឧបករណ៍អប់រំសម្រាប់គ្រូនិងនិស្សិតនឹងត្រូវបានពិពណ៌នាដូចខាងក្រោម។ឧបករណ៍ទាំងនេះជួយឆ្លុះបញ្ចាំង ពីការរៀនអនុវត្ត ពីសកម្មភាពដែលហៅថាទំនាក់ទំនងនិងបង្ហាញចំណេះដឹងរបស់របស់និស្សិត។ សកម្មភាពទាំងនេះក៏បានគាំទ្រដល់ការផ្សារភ្ជាប់ផងដែររវាង ចំណេះដឹងនិងការអនុវត្ត។

### ២.៥.១ **MOOCs** (Massive Open Online Courses)

និស្សិតនឹងអាចៈ
ក្នុងកំឡុងពេលមួយសប្តាហ៍ដំបូងក្នុងការបង្រៀនមេរៀននៃ៨ ម៉ូឌុល ក្នុងវគ្គសិក្សា SafeMa
និស្សិតនឹងចូលរួមនៅក្នុង MOOCs ។ MOOCsទាំងនេះនឹងបញ្ចូលទូទៅ ស្រដៀងវគ្គសិក្សា SafeMa ។
លើសពីនេះនឹងបញ្ចូល ស្សនៈវិជ្ជា  ដូចជាសកម្មភាពរៀន
និងវត្ថុបំណងជាក់លាក់នៃម៉ូឌុលបានបង្ហាញដល់និស្សិត។  បន្ថែមលើនេះនឹងមានការពន្យល់អំពី
ម៉ូឌុលនីមួយៗហើយនឹងមានទំនាក់ទំនងពីម៉ូឌុលមួយទៀតដើម្បីនិស្សិតទទួលបានសមត្ថភាព
ទាំងនេះជាផ្នែកមួយ នៃ MOOCs ។

ការដៅ ជាក់លាក់មួយនឹងត្រូវបានផ្តល់ប្រាក់ក្នុងពេលរៀបចំ
ប៉ុន្តែលុះត្រាតែខ្លឹមសារទាំងនោះត្រូវបានចូលចិត្តពី អ្នកប្រើប្រាស់MOOCSផងដែរ
ដើម្បីធ្វើឱ្យប្រសើរឡើងតាមដែលអាចធ្វើទៅបានទាក់ទងនឹងប្រសិទ្ធភាពនៃបទពិសោធន៍របស់គ្រូបង្វឹក។
ការរៀបចំការណែនាំនិងវីដេអូខ្លីអំពីរបៀបប្រើ នឹងត្រូវបានបង្កើតនិងដាក់បញ្ចូល
អ្នកប្រើក៏នឹងត្រូវបានបង្កើតតាមនិយាមស្តង់ដារអន្តរជាតិផងដែរ។

សេវាកម្មនិងផលិតផលទាំងអស់របស់ SafeMa នឹងគោរពតាមកម្មសិទ្ធិបញ្ញាតាមនិយាមស្តង់ដា និងការណែនាំរបស់សហភាពអឺរ៉ុប ។



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

យោងតាមការបង្កើតខ្លឹមសារនិងអ្នកប្រើប្រាស់នៃភាគីទីបីយល់ព្រមពីអ្នកនិពន្ធនឹងត្រូវបានធានា ឬការផ្តល់អាជ្ញាប័ណ្ណលក្ខខណ្ឌទូទៅនឹងត្រូវបានរាប់បញ្ចូលរាល់ការប្រគល់គម្រោង។

### ២.៥.២ បាឋកថា (Lectures)

ការបាឋកថានឹងធ្វើឡើងដោយគ្រូ មកពីសាកលវិទ្យាល័យដៃគូក្នុងតំបន់អាស៊ាន។ បាឋកថាគឺជួយនិស្សិតឱ្យចេះប្រើសម្ភារ។ បាឋកថានឹងត្រូវបានរៀបចំឡើងដោយផ្អែកលើការរំពឹងទុកថានិស្សិតនឹងត្រូវទទួលចំណេះសម្រាប់បាឋាកថា ហើយចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពសិក្សា។

### ២.៥.៣ ការរៀបចំ (Preparation)

ត្រូវបានគេរំពឹងថានិស្សិតនឹងត្រៀមខ្លួនក្នុងការចូលរួមតាមកាលវិភាគនៃការបង្រៀន ការបណ្តុះបណ្តាលជំនាញ ការធ្វើតេស្ត និងសកម្មភាពសិក្សាដែលបានគ្រោងទុកផ្សេងទៀតដូចជាការពិភាក្សាជាក្រុមនិងធ្វើការងារជាក្រុម។

### ២.៥.៤ ការងារជាក្រុម (Group work)

ការងារជាក្រុមគឺជាវិធីរៀនមួយដ៏មានប្រសិទ្ធភាព (៩) ហើយវានឹងក្លាយជាផ្នែកមួយនៃវគ្គសិក្សារបស់ SafeMa ។ វាជាការឆ្លុះបញ្ចាំងគ្នាទៅវិញទៅមកនិងគាំទ្រនិស្សិត ពិភាក្សាក្នុងពេលបំពេញការងារដែលគ្រូដាក់ឲ្យធ្វើ។ ការងារជាក្រុមនឹងត្រូវបានអនុវត្ត រំពឹងថាវានឹងគាំទ្រដល់ការរៀនប្រកបដោយប្រសិទ្ធភាព។

### ២.៥.៥ ថ្ងៃសិក្សា (Study days)

ថ្ងៃសិក្សាជាផ្នែកមួយ គ្រប់ម៉ូឌុលនៃវគ្គសិក្សា SafeMa ។ ថ្ងៃសិក្សានេះមិនរាប់បញ្ចូលពីការបង្រៀនឬសកម្មភាពសិក្សាដែលបានគ្រោងនៅសាលាឡើយ។ ថ្ងៃទាំងនេះសម្រាប់គ្រប់ម៉ូឌុលដើម្បីសិក្សាពេញម៉ោង  តម្រូវការសិក្សា ការរៀបចំ ការធ្វើរកិច្ចការ ដូចជាវត្តមានក្នុងថ្នាក់ ការពិនិត្យឡើងវិញនូវ MOOCs ឬសម្ភារនិម្មិតផ្សេងៗទៀត។

### ២.៥.៦ កិច្ចការត្រូវបំពេញ (Assignment)

ការរៀបចំកិច្ចការត្រូវបំពេញនឹងជាផ្នែកភ្ជាប់រវាងម៉ូឌុលនិងកម្មសិក្សាគ្លីនិក។ កិច្ចការត្រូវបំពេញទាំងនេះអាចប្រមូលបញ្ហាផ្សេងៗលុះត្រាតែនិស្សិតចូលរួម រៀបចំជាការងារតូចៗ លំហាត់ ក្នុងកំឡុងពេលសិក្សាម៉ូឌុល។ កិច្ចការដែលត្រូវបំពេញនេះផ្តោតលើកម្រិតជំនាញវិជ្ជាជីវៈ និងអភិវឌ្ឍជំនាញវិជ្ជាជីវៈក៏ដូចជាសមត្ថភាព។ ពួកគេអាចធ្វើជាលក្ខណៈបុគ្គលម្នាក់ៗឬជាក្រុម។ គោលបំណងនៃការងារទាំងនេះគឺចង់ឲ្យនិស្សិតអាចផ្សាភ្ជាប់ចំណេះដឹងថ្មីៗទៅនឹងការងារវិជ្ជាជីវៈជាក់លាក់របស់ពួកគេ ក្នុងពេលត្រៀមខ្លួន ក្នុងពេលរៀន និងក្នុងពេលចុះកម្មសិក្សាគ្លីនិក ។ នេះដើម្បីផ្សារភ្ជាប់គម្លាតនិងបង្កើតទំនាក់ទំនងយ៉ាងជិតស្និទ្ធសម្រាប់និស្សិតរវាងទស្សនៈវិស័យទ្រឹស្តីនិងការអនុវត្តជាក់ស្តែងនៃនិស្សិត SafeMa។ វិធីសាស្ត្រនេះត្រូវបានគេជឿជាក់ថានឹងគាំទ្រដល់ការអនុវត្តតាមរយៈការឆ្លុះបញ្ចាំង ដូច្នេះនិស្សិតនឹងមានការគិតនិងសមត្ថភាពក្នុងការសំរេចចិត្តបានដោយខ្លួនឯង។

និស្សិតគួរតែមានការណែនាំ អំពីការងារដែលត្រូវរៀបចំឡើង និងចងក្រងជាឯកសារជាបន្តបន្ទាប់ក្នុងអំឡុងពេលសិក្សា។ ការរួមបញ្ចូលទាំងពិពណ៌នាសម្រាប់ការងារនីមួយៗ ការបញ្ជាក់អំពីវិសាលភាពដែលរំពឹងទុក និងតម្រូវការបរិក្ខាសម្រាប់ដាក់ស្នើសុំក៏ដូចជាលទ្ធភាពនៃការឆ្លើយតប (feedback)។

### ២.៥.៧ ការប្រឡង/ ការធ្វើតេស្ត (Exams/tests)

នៅចុងបញ្ចប់នៃ MOOC ប្រើក្នុងសប្តាហ៍ដំបូងនៃម៉ូឌុលនីមួយៗ ការធ្វើតេស្តមួយនឹងត្រូវបានអនុវត្ត។ និស្សិតត្រូវតែឆ្លងកាត់ការធ្វើតេស្តនេះមុនពេលបន្តសិក្សាលើម៉ូឌុលផ្សេងៗទៀត។ ដូចគ្នានេះដែរ គ្រប់ម៉ូឌុលនិងកម្មសិក្សាគ្លីនិកនឹងបញ្ចប់ដោយការប្រឡង។



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ការបំពេញគ្រប់ការប្រឡងទាំងនេះតម្រូវឱ្យបន្តការសិក្សា ម៉ូឌុលបន្តទៀត។ និស្សិតរំពឹងថានឹងទទួលបានវិញ្ញាបនប័ត្រ នៅពេលបញ្ចប់វគ្គសិក្សានៃម៉ូឌុលទាំង៤ ឬទាំង៨ រួមទាំងកម្មសិក្សាគ្លីនិកផងដែរ។ ការធ្វើតេស្តឬសំណួរអាចជួយគាំទ្រដល់ការរៀនរបស់និស្សិត ហើយវាក៏ជាផ្នែកមួយនៃការបង្រៀនផ្សេងៗគ្នាក្នុងកំឡុងពេលបង្រៀនម៉ូឌុលទាំង៨នេះផងដែរ។

២.៥.៨ គ្រឿងបរិក្ខារ (Facilities )

នៅតាមសាកលវិទ្យាល័យដៃគូអាស៊ានទាំងអស់ មណ្ឌល SafeMa (SafeMa Hubs) នឹងត្រូវបានតម្លើង ដែលនឹងប្រើ ធ្វើជាគំរូសម្រាប់ការបង្រៀន ការស្រាវជ្រាវ គរុកោសល្យ និងជាមណ្ឌលសម្រាប់ការណែនាំនៅក្នុងជំនាញឆ្មប (WP ២.៣) ។ មណ្ឌល SafeMa នឹងគាំទ្រឆ្មបនៅតាមថ្នាក់មូលដ្ឋាននិងថ្នាក់តំបន់ និងធ្វើការជាដៃគូជាមួយមន្ទីរពេទ្យ មណ្ឌលសុខភាពនៅតំបន់ជនបទ គម្រោង UNFPA អាជ្ញាធរមូលដ្ឋាន សមាគមឆ្មបជាតិ និងអ្នកពាក់ព័ន្ធដទៃទៀតដើម្បីជានាបាននូវសកម្មភាពមណ្ឌល SafeMa ប្រតិបត្តិការដ៏មានប្រសិទ្ធិភាព ។ការអភិវឌ្ឍកម្មវិធីសិក្សានិង និងមណ្ឌល SafeMa (WP២.១+៣) នឹងពឹងផ្អែកទៅលើដៃគូអាស៊ាននីមួយៗដែលផ្តល់នូវការពិពណ៌នានៅក្នុងផែនការ SafeMa សម្រាប់ឧត្តមភាព (WP ១.៥) ។ ចំណុចនេះគួរតែផ្តោតលើស្តង់ដារនៃរបាយការណ៍នេះហើយរួមបញ្ចូលទាំងគោលបំណងជាក់ស្តែងនិងពេលវេលាដែលនឹងត្រូវមានការចូលរួមគាំទ្រពីថ្នាក់ដឹកនាំរបស់ស្ថាប័នក៏ដូចជាបុគ្គលិកនិងនិស្សិត (១) ។

២.៥.៩ គន្លឹះពិចារណាសម្រាប់ **WP** ១.៥ របស់គម្រោងឧត្តមភាព (Considerations for WP1.5 Excellency plans)

ការអភិវឌ្ឍកម្មវិធីសិក្សា និងការបង្កើតមណ្ឌល SafeMa (WP២.១+ ៣) នឹងពឹងផ្អែកលើដៃគូអាស៊ាននីមួយៗដែលផ្តល់ការពិពណ៌នាគ្រប់គ្រាន់សម្រាប់ផែនការរបស់ពួកគេសម្រាប់ការអភិវឌ្ឍមណ្ឌល (Hub) តាមផែនការ (WP ១.៥)។ ទាំងនេះគួរតែផ្អែកលើស្តង់ដារនៃការធ្វើបទបង្ហាញ និងការរួមបញ្ចូលគោលបំណងនិងពេលវេលាជាក់លាក់ដែលនឹងត្រូវមានការចូលរួមគាំទ្រពីថ្នាក់ដឹកនាំរបស់ស្ថាប័នក៏ដូចជាបុគ្គលិកនិងនិស្សិត។

៣. ប្លង់ នៃម៉ូឌុលទាំង ៨ (Outline of the 8 modules )

ម៉ូឌុលទាំង៨នឹងត្រូវបានបង្ហាញខាងក្រោមនេះ ។ ខ្លឹមសារទូទៅនៃម៉ូឌុល ត្រូវបានបង្កើតឡើងក្នុងកំឡុងពេលនៃដំណើរទស្សនកិច្ចសិក្សារបស់ SafeMa នៅប្រទេសដាណឺម៉ាកក្នុង



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

Co-funded by the
Erasmus+ Programme
of the European Union

ខែវិច្ឆិកាឆ្នាំ ២០១៩ ដែលដៃគូ SafeMa ទាំងអស់បានចូលរួមក្នុងការស្នើសុំមាតិកានៃម៉ូឌុល។




រូបភាពទី ១:
រូបភាពពីដំណើរទស្សនកិច្ចសិក្សានៅប្រទេសដាណឺម៉ាក:ក្រុមប្រឹក្សាភិបាលដោយមានយោបល់ពីដៃគូ SafeMa សម្រាប់បរិបទម៉ូឌុល

បន្ទាប់ពីដៃគូ SafeMa បានផ្តល់នូវយោបល់អំពីមាតិកានៃម៉ូឌុល និងវិភាគបន្ទាន់បាន អភិវឌ្ឍមាតិកានៃម៉ូឌុល។ ការវិភាគបែបអាដហុក (Ad Hoc analysis) មានចំណុចដូចខាងក្រោម:

- ការផ្តល់យោបល់របស់ដៃគូរ SafeMa ពីមាតិការរបស់ម៉ូឌុល
- របាយការណ៍WP១.១: ឧត្តមភាពសិក្សានិងស្រាវជ្រាវក្នុងវិស័យអប់រំឆ្មបព្រមទាំងស្រាវជ្រាវ
- វគ្គឆ្លុះបញ្ចាំងក្នុងដំណើរទស្សនកិច្ចសិក្សាជាក់លាក់នៅដាណឺម៉ាកនិងការសង្កេតមើលពីដំណើរទស្សនកិច្ចសិក្សានៅអាតែន
- ការសន្ទនាក្រៅផ្លូវការជាមួយដៃគូ SafeMa ក្នុងពេលចាប់ផ្តើមការប្រជុំនិងទស្សនកិច្ចសិក្សានៅដាណឺម៉ាកនិងអាតែន។
- WP១.២ របាយការណ៍ការវិភាគ SafeMa

ដើម្បីទទួលបានខ្លឹមសារល្អនៃម៉ូឌុល SafeMa ឯកសារ ICM ដែលស្តីពីសមត្ថភាពចាំបាច់សម្រាប់ការអនុវត្តឆ្មបឆ្នាំ២០១៩ដែលបានធ្វើបច្ចុប្បន្នភាពត្រូវបានដាក់បញ្ចូល (១០) ។  ឯកសារ ICM ក៏បាឆ្លុះបញ្ចាំងទស្សនៈវិជ្ជា ICM និងគំរូថែទាំរបស់ឆ្មបបន្ថែមលើនិយមន័យ ICM និងវិសាលភាពអនុវត្តរបស់ឆ្មប។ ពួកគេមានវិធីសាស្រ្តរួម អនុវត្តដោយឆ្មប បន្ទាប់កែសម្រួលការណែនាំទស្សនៈវិជ្ជា SafeMa (១០)។ គោលការណ៍ណែនាំទាំងនេះត្រូវបានរៀបរាប់ដូចខាងក្រោមដោយវាត្រូវបានចាត់ទុកជាការលើកកម្ពស់ខាងផ្នែកៈ

- ស្វ័យភាពរបស់ឆ្មបទៅលើវិសាលភាពអនុវត្តន៍នៅគ្រប់ទីកន្លែង
- តួនាទីរបស់ឆ្មបក្នុងការគាំទ្រដល់សរីរវិទ្យានិងលើកកម្ពស់ការសម្រាលដោយធម្មជាតិ។



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

- តួនាទីរបស់ឆ្មបក្នុងការលើកស្ទួយសិទ្ធិមនុស្ស ដំណើរការយល់ព្រម និងការសម្រេចចិត្តរបស់ស្រី។
- តួនាទីរបស់ឆ្មបក្នុងការលើកកម្ពស់ការអនុវត្តជាក់ស្តែង រួមទាំងបន្ថយអន្តរាគមន៍ដែលពុំចាំបាច់
- តួនាទីរបស់ឆ្មបក្នុងការវាយតំលៃ រោគវិនិច្ឆ័យ ការធ្វើអន្តរាគមន៍ ពិគ្រោះយោបល់ និងការបញ្ជូនជាចាំបាច់ រួមទាំងការផ្តល់អន្តរាគមន៍បន្ទាន់ (១០) ។

## ៣.១ បទបង្ហាញម៉ូឌុលទាំង ៨របស់គម្រោង SafeMa (Presentation of the 8 SafeMa modules)

ខាងក្រោមនេះគឺជាបទបង្ហាញនៃម៉ូឌុលទាំង៨។ បទបង្ហាញរួមបញ្ចូលទាំងមាតិកានៃម៉ូឌុល លទ្ធផលការសិក្សា និងការពិនិត្យក្រាហ្វិចនៃម៉ូឌុល។ លទ្ធផលនៃការសិក្សាត្រូវបានរៀបចំឡើងជា៣ផ្នែកៈ សមត្ថភាព ចំណេះដឹង និងជំនាញ។ ម៉ូឌុលនឹងត្រូវបានបង្កើតឡើងក្នុងកម្រិតជាក់លាក់មួយ ដោយដៃគូដែលទទួលខុសត្រូវចំពោះកម្មវិធី WP២។ វាត្រូវមានការចូលរួមពីដៃគូទាំងអស់ដើម្បីបង្ហាញពីក្របខណ្ឌលម្អិត បញ្ជីមុខវិជ្ជា និងឧបករណ៍ជាក់លាក់សិក្សា (Learning tools) ដូចជាឧបករណ៍ប្រើប្រាស់សំរាប់វគ្គសិក្សារបស់ SafeMa ជាដើម។

នៅក្នុងបែងចែកនូវរចនាសម្ព័ននៃវគ្គសិក្សា SafeMa សាស្ត្រាចារ្យរបស់ SafeMa នៅតាមសាកលវិទ្យាល័យដៃគូនៅប្រទេសវៀតណាម និងប្រទេសកម្ពុជាត្រូវបានរំពឹងទុកថានឹងចូលរួមចំណែកដល់ការបង្កើតនូវរចនាសម្ព័ន្ធនៃកម្មវិធីសិក្សា និងសកម្មភាពសិក្សាផ្សេងៗដែលអាចជួយឱ្យនិស្សិត ក្នុងវគ្គ SafeMa ទទួលបានជំនាញ ចំណេះដឹង និងសមត្ថភាពដែលត្រូវបានបង្ហាញនៅក្នុងលទ្ធផលនៃការសិក្សានីមួយៗ ។ ទាំងនេះគឺដើម្បីគាំទ្រដល់ការអនុវត្តនិងនិរន្តរភាពនៃគម្រោង SafeMa នៅក្នុងបរិបទមូលដ្ឋាននីមួយៗ។

## ៣.២ ម៉ូឌុលទី ១៖ ការធ្វើឲ្យប្រសើឡើងនូវជំនាញគ្លីនិកឆ្មប-ការលើកកម្ពស់ឲ្យមានការឈឺពោះសម្រាលកូនធម្មតា (Module 1: Advanced clinical skills in midwifery – promoting normal labor)

### ៣.២.១ មាតិការ (Content)

ប្រធានបទនេះទាក់ទងនឹងការលើកកម្ពស់លើការឈឺពោះសម្រាលធម្មតាក្នុងការថែទាំរបស់ឆ្មប ដែលរួមមានការប្រើប្រាស់វិធីបំបាត់ការឈឺចាប់ដែលមិនមែនជាការប្រើឱសថ ការការពារសុវត្ថិភាពអ្នកជំងឺ និងការជៀសវាងពីអន្តរាគមន៍វេជ្ជសាស្ត្រដែលមិនចាំបាច់។ ការយកចិត្តទុកដាក់ទាំងនេះគឺផ្តោតលើការអនុវត្តនិងការអភិវឌ្ឍជំនាញគ្លីនិក ការគ្រប់គ្រងនិងចំណេះដឹងផ្នែកជំនាញគ្លីនិកក្នុងកំឡុងពេលសំរាលធម្មតា។

### ៣.២.២ លទ្ធផលនៃការសិក្សា (Learning outcomes)

លទ្ធផលនៃការសិក្សាគឺរំពឹងទុកថា នៅចុងបញ្ចប់នៃម៉ូឌុល១និស្សិតនឹងមាន សមត្ថភាព ចំណេះដឹង និងជំនាញ ។ ក្នុងអំឡុងពេលនៃការបង្រៀនម៉ូឌុលនីមួយៗ របស់វគ្គសិក្សា SafeMa គ្រូបង្រៀនស្របទៅតាមលទ្ធផលនៃម៉ូឌុលទាំងនេះ។

### ៣.២.៣ សមត្ថភាពនិស្សិត (Competencies)

នៅចុងបញ្ចប់ម៉ូឌុល ១ នៃវគ្គសិក្សា SafeMa និស្សិតនឹងអាចលើកកម្ពស់និងគ្រប់គ្រងការឈឺពោះសម្រាលធម្មតា ក្នុងខណៈពេលឆ្មបខិតខំលើកកម្ពស់សម្រាលកូនធម្មតា និងឲ្យមានសុវត្ថិភាពស្ត្រី ។

### ៣.២.៤ ចំណេះដឹងនិស្សិត (Knowledge)

នៅចុងបញ្ចប់នៃម៉ូឌុលទី១នៃវគ្គ SafeMa និស្សិតនឹងអាចៈ

- កំណត់និងពិពណ៍នាអំពីជីវសាស្ត្រ ចិត្តសាស្ត្រ សង្គមសាស្ត្រ និងវប្បធម៌ផ្សេងៗនៃការឈឺពោះសម្រាលធម្មតា។
- កំណត់និងពិពណ៍នាអំពីកាយវិភាគវិទ្យានិងសរិរវិទ្យានៃការឈឺចាប់ផ្តើមពោះសម្រាលធម្មតា និងការវិវត្តនៃការឈឺពោះសម្រាលធម្មតា។



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

- កំណត់និងពិពណ៌នាអំពីសញ្ញានិងអាកប្បកិរិយាពីការវិវត្តនៃការសម្រាលធម្មតានិងកត្តារារាំងដល់ការវិវត្តនៃការឈឺពោះសម្រាល
- កំណត់និងរៀបរាប់វិធីសាស្ត្រសម្រាប់ព័ត៌មានការថែទាំក្នុងពេលប្រសូតនិងការណែនាំរួមទាំងជៀសវាងការអន្តរាគមន៍នៅក្នុងពេលនៃការឈឺពោះសម្រាល និងសម្រាលធម្មតា
- កំណត់និងរៀបរាប់ លើកឧទាហរណ៍អំពីការមិនប្រើឱសថដើម្បីបន្ថយការឈឺចាប់ដោយលៀបនិងវិធីសាស្ត្រផ្សេងៗ។
- កំណត់និងពណ៌នាពីបញ្ហាចំបងនៃសុវត្ថិភាពរបស់អ្នកជំងឺក្នុងការគ្រប់គ្រងការឈឺពោះសម្រាល
- វិភាគតួនាទីរបស់ឆ្មបក្នុងការលើកកម្ពស់ឲ្យមានការឈឺពោះសម្រាលធម្មតា។
- វិភាគតួនាទីរបស់ឆ្មបទៅនឹងការឈឺពោះសម្រាលធម្មតាដែលលើកកម្ពស់ការគោរពទៅលើភាពស្មោះត្រង់របស់អ្នកជំងឺខណៈពេលដែលប្រើប្រាស់វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស។

៣.២.៥ ជំនាញ (Skills)

នៅចុងបញ្ចប់នៃម៉ូឌុលទី១នៃវគ្គ SafeMa អ្នកចូលរួមនឹងអាចៈ

- វាយតម្លៃពីតំរូវការសម្រាប់ការព្យាបាលនិងបំបាត់ការឈឺចាប់ដែលមិនប្រើឱសថនៅពេលឈឺពោះសម្រាលធម្មតា។
- ផ្តល់ជូននិងគាំទ្រស្ត្រីឱ្យប្រើយុទ្ធសាស្ត្រក្នុងការសម្រួលការឈឺចាប់ក្នុងពេលឈឺពោះសម្រាល ឧទាហរណ៍ៈ ការត្រួតពិនិត្យការដកដង្ហើម ការម៉ាស្សា ការសំរាក ការម៉ាស្សា និងប្រើឱសថនៅពេលចាំបាច់។
- ការពារការធ្វើអន្តរាគមន៍ផ្អែកវេជ្ជសាស្ត្រដែលមិនចាំបាច់ក្នុងពេលឈឺពោះសម្រាល
- គាំទ្រសុវត្ថិភាពអ្នកជំងឺ។
- លើកទឹកចិត្តឱ្យមានសេរីភាពក្នុងការធ្វើចលនា។
- គាំទ្រស្ត្រីឱ្យផ្តល់កំណើតតាមជំរើសរបស់នាង។
- វាយតម្លៃរាងកាយស្ត្រីនិងអាកប្បកិរិយារបស់ស្ត្រីពេលឈឺពោះសម្រាល។
- វាយតម្លៃជាប្រចាំនៃស្ថានទូវភាពមាតានិងទារក។ ឧ.សញ្ញាជីវិត ការកន្ត្រាក់ស្បូន និងការចុះនៃក្បាលទារក។
- ការបង្ការកុំធ្វើអន្តរាគមន៍ ដែលមិនចាំបាច់ ឧ.ចោះបំបែកទឹកភ្លោះ ការត្រួតពិនិត្យទារកតាមអេឡិចត្រូនិច, ការរុញពោះ និងការកាត់ទ្វារមាស។
- ពន្យារពេលនៃការកៀបទងសុក
- បញ្ចូលវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្សទៅក្នុងការអនុវត្ត។

៣.២.៦ ប្លង់នៃម៉ូឌុល (Outline of the module)




សូមជ្រាប

៣.២.៧ P1.5

Excellen

ដៃគូអាស៊ានគួរតែដឹងថា ការធ្វើសមាហរណកម្មជាពិសេសអ្នកដែលមានរូបគំរូម៉ានីកាំង (advanced



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

mannequins) មិនចាំបាច់ប្រើសម្រាប់ការប្រតិបត្តិនៃម៉ូឌុលនេះទេ។ វិធីសាស្រ្តសម្រាប់អនុវត្តន៍បំបាត់ការឈឺចាប់ដោយមិនប្រើឱសថនឹងត្រូវការប្រើជាចាំបាច់។

៣.៣ ម៉ូឌុលទី ២៖ ការអនុវត្តជំនាញគ្លីនិកកម្រិតខ្ពស់ ឆ្មបទី២ - ការតាមដានគភ៌និងសុវត្ថិភាពម្តាយ (Module 2: Advanced clinical skills in midwifery II – Fetal monitoring and patient safety)

៣.៣.១ មាតិការ (Content)

ប្រធានបទនេះទាក់ទងនឹងការបង្ហាញនិង ការបកស្រាយពីការតាមដានគត៌ក្នុងផ្ទៃកំឡុងពេលឈឺពោះសម្រាល។ ការផ្តោតនេះដើម្បីសុវត្ថិភាពស្ត្រី ការអនុវត្តនិងការអភិវឌ្ឍជំនាញគ្លីនិក និងការគ្រប់គ្រងក្នុងកំឡុងពេលសំរាលធម្មតានិងការសំរាលដោយមានឧបសគ្គ។

៣.៣.២ លទ្ធផលនៃការសិក្សា (Learning outcomes)

លទ្ធផលនៃការសិក្សាត្រូវបានរំពឹងទុកថាចុងបញ្ចប់នៃម៉ូឌុលនឹងមាន សមត្ថភាព ចំណេះដឹង និងសមត្ថភាពជំនាញ។ ក្នុងអំឡុងពេលបង្រៀនម៉ូឌុលនីមួយៗ របស់វគ្គ SafeMa គួរតែបង្រៀនទាក់ទងនឹងលទ្ធផលនៃការសិក្សាទាំងនេះ។

៣.៣.៣ សមត្ថភាពនិស្សិត (Competencies)

នៅចុងបញ្ចប់ម៉ូឌុលទី២នៃវគ្គ SafeMa និស្សិតនឹងអាចគ្រប់គ្រងវិធីសាស្រ្តសម្រាប់ការតាមដានទារកក្នុងកំឡុងពេលមានផ្ទៃពោះ និងផលវិបាកនៃការមានផ្ទៃពោះ និងការសម្រាល ខណៈរៀនបញ្ចូលគ្នាទាំងទ្រឹស្តីនិងអនុវត្ត ដើម្បីបង្កើនសុវត្ថិភាពស្ត្រី។

៣.៣.៤ ចំណេះដឹងនិស្សិត (Knowledge)

នៅចុងបញ្ចប់ម៉ូឌុលទី២នៃវគ្គ SafeMa និស្សិតនឹងអាច៖

- កំណត់និងរៀបរាប់ពីវិធីតាមដានទារកក្នុងពេលមានផ្ទៃពោះនិងពេលឈឺពោះសម្រាល ។
- កំណត់និងពណ៌នាអំពីទារក ទារកនៅក្នុងស្បូនធម្មតា ទៅទារកនៅខាងក្រៅស្បូននិងសញ្ញាដែលបង្ហាញពីភាពចាំបាច់សម្រាប់ជួយសង្គ្រោះបន្ទាន់។
- កំណត់ និងពណ៌នាពីផលវិបាកដែលបណ្តាលមកពីការថប់ដង្ហើមរបស់ទារក(asphyxia)
- កំណត់និងពណ៌នាវិសាលភាពនៃការសម្រាលដើម្បីវាយតម្លៃស្ថានភាពទារកទើបកើត។
- កំណត់និងពណ៌នាការអន្តរាគមន៍ ដើម្បីវាយតម្លៃចង្វាក់ដង្ហើមនិងចរន្តឈាមទារកទើបនឹងកើត
- កំណត់និងពណ៌នាអំពីការងារចំបងនិងសុវត្ថិភាពរបស់ស្ត្រីដើម្បីគ្រប់គ្រងការឈឺពោះសម្រាលមានឧបសគ្គ
- កំណត់និងរៀបរាប់ពីវិធីសាស្រ្តសម្រាប់សុវត្ថិភាពរវាងអន្តរបុគ្គលជំនាញវិជ្ជាជីវៈ
- វិភាគតួនាទីឆ្មបក្នុងការតាមដានគត៌ដោយលើកកម្ពស់ការគោរព ភាពស្មោះត្រង់របស់ស្ត្រីដោយប្រើប្រាស់សិទ្ធិមនុស្សជាមូលដ្ឋាន។

៣.៣.៥ ជំនាញ (Skills)

នៅចុងបញ្ចប់នៃម៉ូឌុលទី២នៃវគ្គ SafeMa និស្សិតនឹងអាច៖

- ប៉ាន់ប្រមាណពីភាពចាំបាច់សំរាប់ការអនុវត្តវិធីសាស្រ្តប្លែកៗនៃការតាមដានទារកក្នុងកំឡុងពេលឈឺពោះសម្រាលធម្មតានិងពេលមានផលវិបាក។
- ប្រើនិយាមស្តង់ដាដើម្បីវាយតម្លៃ ស្ថានភាពទារកទើបនឹងកើតក្នុងនាទីដំបូងនៃជីវិត (Apgar ឬផ្សេងទៀត) និងតម្រូវការផ្សេងៗទៀត ប្រសិនបើចាំបាច់
- ធ្វើសកម្មភាពនិងគាំទ្រដល់ចង្វាក់ដង្ហើម អុកស៊ីសែននិងការព្យាបាលបើចាំបាច់
- ការពារដល់ទារកទើបនឹងកើត ឧ. ការចម្លងរោគលើភ្នែក និងជំងឺបង្ករឲ្យមានការហូរឈាម តាមគោលការណ៍និងងការណែនាំ



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

- ធ្វើឲ្យឆ្មបមានការកិច្ចប្រកបដោយមានជំនាញគ្លីនិក
- ជួយឲ្យស្ត្រីមានសុវត្ថិភាពក្នុងកំឡុងពេលឈឺពោះសម្រាលពេលមានឧបសគ្គ
- សហការនិងប្រាស្រ័យទាក់ទងជាមួយស្ត្រីមានផ្ទៃពោះ ស្ត្រីកំពុងឈឺពោះសម្រាលនិងក្រុមគ្រួសាររបស់គាត់
- ប្រើប្រាស់ជំនាញអន្តរបុគ្គលដើម្បី ប្រាស្រ័យទាក់ទង ដូចជាវិធីសាស្ត្រ ISBAR
- ប្រើប្រាស់វិធីសាស្ត្រតាមដានគត់ ដោយលើកកម្ពស់ការគោរពចំពោះសិទ្ធអតិថិជនខណៈប្រើសិទ្ធិមនុស្សជាមូលដ្ឋាន។

៣.៣.៦ ប្លង់នៃម៉ូឌុល (Outline of the module)




៣.៣.៧ គន្លឹះពិចារណា **WP.**១.៥ ផែនការឧត្តមភាព (Considerations for WP1.5 Excellency plans)

នៅពេលបង្កើត WP១.៥ ផែនការឧត្តមភាពសម្រាប់ម៉ូឌុលនេះ ដៃគូអាស៊ាន នឹងចេះប្រើ advanced mannequins ពិសេសឧបករណ៍ ដែលមាន Software មិនចាំបាច់ទេសម្រាប់ការប្រតិបត្តិនៃម៉ូឌុលនេះទេ។ ឧបករណ៍ការអនុវត្តទារកគំរូសម្រាប់តាមដានចាំបាច់ប្រើ។ ក្នុងអំឡុងពេលនៃការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ម៉ូឌុល SafeMa គ្រូរបស់សាកលវិទ្យាល័យត្រូវតែផ្តត់ផ្គង់ទាក់ទងករណីតាមដានគត់ និងការប្រាស្រ័យទាក់ទង ដែលឆ្លើយតបទៅបរិបទក្នុងសាកលវិទ្យាល័យ ពីព្រោះវាជាការលំបាកសម្រាប់ដៃគូសហភាពអឺរ៉ុបក្នុងការផលិតដោយគ្មានចំណេះដឹងនៅក្នុងបរិបទមូលដ្ឋាននេះ។

៣.៤ ម៉ូឌុលទី ៣៖ ការអនុវត្តគ្លីនិកកម្រិតខ្ពស់ ឆ្មបទី ៣ ការសង្គ្រោះបន្ទាន់ម្តាយនិងទារក (MODULE 3: Advanced clinical skills in midwifery III – Obstetric emergencies)

៣.៤.១ មាតិការ (Content)

ប្រធានបទនេះទាក់ទងនឹងការសង្គ្រោះបន្ទាន់នៃ shoulder dystocia និងជួយស្ត្រីឲ្យមានសុវត្ថិភាព ទាក់ទងផលវិបាកក្រោយសម្រាលដែលទាក់ទងទៅនឹងការធ្លាក់ឈាមច្រើន។ ការផ្តោតសំខាន់លើការអនុវត្តនិង ការអភិវឌ្ឍជំនាញគ្លីនិក និងការគ្រប់គ្រងក្នុងកំឡុងពេលសម្រាលដែលមានឧបសគ្គ។

៣.៤.២ លទ្ធផលនៃការសិក្សា (Learning outcomes)

លទ្ធផលនៃការសិក្សាគឺត្រូវបានរំពឹងទុកនឹងកើនសមត្ថភាព ចំណេះដឹង និងជំនាញ ដែលនិស្សិត SafeMa ទទួលបាននៅចុងបញ្ចប់នៃម៉ូឌុលនីមួយៗ។ ក្នុងអំឡុងពេលនៃការបង្រៀនម៉ូឌុលនៃវគ្គសិក្សា SafeMa គ្រូនឹងសម្រេចលទ្ធផលបង្រៀនស្របទៅតាមលទ្ធផលនៃការសិក្សាខាងដើម។

៣.៤.៣ សមត្ថភាពនិស្សិត (Competencies)



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

Co-funded by the Erasmus+ Programme of the European Union

នៅចុងបញ្ចប់ម៉ូឌុលទី៣ នៃ SafeMa និស្សិតនឹងអាចគ្រប់គ្រងការសង្គ្រោះបន្ទាន់ shoulder dystocia និងជួយស្ត្រីឲ្យមានសុវត្ថិភាពទាក់ទងផលវិបាកក្រោយសម្រាលដែលទាក់ទងទៅនឹងការធ្លាក់ឈាមច្រើន។ ការផ្តោតសំខាន់លើការអនុវត្តនិង ការអភិវឌ្ឍជំនាញគ្លីនិក និងការគ្រប់គ្រងក្នុងកំឡុងពេលសម្រាលដែលមានឧបសគ្គ។

៣.៤.៤ ចំណេះដឹងនិស្សិត ( Knowledge)

នៅចុងបញ្ចប់ម៉ូឌុលទី៣ នៃ វគ្គSafeMa អ្នកចូលរួមនឹងអាចធ្វើបាន៖

- កំណត់និងរៀបរាប់ពីភស្តុតាងអំពីការអនុវត្តន៍ការងារដំណាក់កាលទីបីនៃការសម្រាលរួមទាំងការគ្រប់គ្រងតំណាក់កាលទី៣
- កំណត់និងពិពណ៌នាអំពីផលវិបាកដែលអាចកើតមានក្រោយពេលសម្រាល និងការព្យាបាលបន្ទាន់ ឧ.ការសម្រាលជាប់ស្មា, ការធ្លាក់ឈាមក្រោយសម្រាលនិងការសល់សុក
- កំណត់ និងរៀបរាប់អំពីសញ្ញានៃការរបេះសុកខុសប្រក្រតី ការលេចចេញនូវសុកមិនធម្មតាភ្នាសនៃសុក និងផលវិបាកនៃការធ្លាក់ទងផ្ចិត។
- កំណត់និងរៀបរាប់ពីវិធីសាស្ត្រដើម្បីដោះស្រាយបញ្ហាការសម្រាលជាប់ស្មាដូចជា បច្ចេកទេស HELPERR
- វិភាគវិធីសាស្ត្រសម្រាប់សុវត្ថិភាពអ្នកជំងឺក្នុងគ្រាមានអាសន្ន ដូចជាការប្រើបច្ចេកទេសដើម្បីធានាសុវត្ថិភាពដល់អ្នកជំងឺ
- វិភាគតួនាទីរបស់ឆ្មបទៅនឹងការសង្គ្រោះបន្ទាន់ផ្នែកសម្ភពដែលគាំទ្រដល់ការគោរពភាពស្មោះត្រង់របស់អ្នកជំងឺខណៈពេលដែលប្រើប្រាស់វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស។

៣.៤.៥ ជំនាញ (Skills)

នៅចុងបញ្ចប់ម៉ូឌុលទី៣នៃវគ្គ SafeMa  អ្នកចូលរួមនឹងអាច៖

- ទំលាក់សុក ស្រោមទឹកភ្លោះ និងពិនិត្យភាពពេញលេញនៃសុក
- ប្រើបច្ចេកទេស HELPERR ដើម្បីគ្រប់គ្រងផ្នែកសម្ភពបន្ទាន់សម្រាប់ការសម្រាលជាប់ស្មា
- វាយតម្លៃពីការកន្ត្រាក់ស្បូនរក្សានូវកម្លាំងនៃការកន្ត្រាក់ខ្លាំងលើកទី១ហើយប៉ាន់ស្មាននិងកត់ត្រាពីការបាត់បង់ឈាម គ្រប់គ្រងការបាត់បង់ឈាមច្រើនពេក។
- ផ្តល់ការព្យាបាលតំបូង ឬជួយសង្គ្រោះឲ្យមកប្រក្រតីឡើងវិញ
- ប្រើបច្ចេកទេសទំនាក់ទំនងដែលធានាសុវត្ថិភាពដល់ស្ត្រី
- ប្រើប្រាស់វិធីសាស្ត្រក្នុងការសង្គ្រោះបន្ទាន់ទារកនិងម្តាយ លើកកម្ពស់ការគោរព ស្ត្រីដោយផ្តោតលើសិទ្ធិមនុស្ស។

៣.៤.៦ ប្លង់នៃម៉ូឌុល (Outline of the module)




សូមជ្រាបថាការផ្លាស់ប្តូរអាចនឹងកើតឡើងក្នុងអំឡុងដំណើរការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ម៉ូឌុល។



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

### ៣.៤.៧ គន្លឹះពិចារណា **WP ១.៥** ឧត្តមភាពផែនការ (Considerations for WP1.5 Excellency plans)

នៅពេលរៀបចំផែនការ WP១.៥ របស់គម្រោងឧត្តមភាពសម្រាប់ផែនការនេះ ដៃគូអាស៊ានគួរតែដឹងថា ការធ្វើសមាហរណកម្មជាពិសេសអ្នកដែលមានរូបគំរូម៉ានីកាំង (advanced mannequins) មិនចាំបាច់ប្រើសម្រាប់ការប្រតិបត្តិនៃម៉ូឌុលនេះទេ។ម៉ានីកាំងសាមញ្ញសម្រាប់អនុវត្តបច្ចេកទេស HELPERR និងឧបករណ៍ធ្វើចលនាផ្សេងទៀតនឹងត្រូវការជាចាំបាច់។

ក្នុងអំឡុងពេលនៃការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ម៉ូឌុល SafeMa គ្រូក្នុងតំបន់ត្រូវតែចូលរួមជួយក្នុងករណីពាក់ព័ន្ធសម្រាប់ភាពបន្ទាន់ផ្នែកសម្ភព និងការប្រាស្រ័យទាក់ទងដែលឆ្លុះបញ្ចាំងពីបរិបទក្នុងតំបន់ ព្រោះនេះជាការពិបាកសម្រាប់ដៃគូសហភាពអឺរ៉ុបក្នុងការ។

## ៣.៥ ម៉ូឌុលទី ៤៖ ការលើកកម្ពស់សុខភាពក្រោយសម្រាលក្នុងការគ្រប់គ្រងរបស់ឆ្មប
(MODULE 4: Post-partum health promotion within midwifery)

### ៣.៥.១ មាតិការ (Content)

ប្រធានបទនេះទាក់ទងនឹងការលើកកម្ពស់សុខភាព និងការការពារសុខភាពដោយឆ្មបក្នុងសម្ភព និងការបំបៅដោះកូន រួមទាំងការយកចិត្តទុកដាក់ចំពោះស្ត្រីដែលមានផលវិបាកទាក់ទងនឹងការបំបៅកូនដោយទឹកដោះ និងការផ្សារភ្ជាប់រវាងម្តាយ ទារក និងការផ្គត់ផ្គង់គ្រួសារជាផ្នែកមួយនៅក្នុងសហគមន៍។ ផ្តោតគាំទ្រទៅលើការអនុវត្ត ការអភិវឌ្ឍជំនាញគ្លីនិក  អន្តរកម្មនិងការទំនាក់ទំនង។

### ៣.៥.២ លទ្ធផលនៃការសិក្សា (Learning outcomes)

លទ្ធផលនៃការសិក្សាបានរំពឹងទុកគឺបង្កើនសមត្ថភាព ចំណេះដឹង និងជំនាញ ដល់និស្សិតសិក្សាក្នុងវគ្គ SafeMa នឹងទទួលបាននៅចុងបញ្ចប់នៃម៉ូឌុល។ ក្នុងអំឡុងពេលនៃការបង្រៀនម៉ូឌុលអ្នកអប់រំក្នុងវគ្គ SafeMa គួរតែបង្រៀនដោយស្របទៅតាមលទ្ធផលនៃការសិក្សាទាំងនេះ។

### ៣.៥.៣ សមត្ថភាពនិស្សិត (Competencies )

នៅចុងបញ្ចប់ម៉ូឌុលទី៤នៃ SafeMa និស្សិតនឹងអាចធ្វើការផ្សព្វផ្សាយពីសុខភាពនិងការការពារសុខភាពដោយឆ្មបនៅក្នុសម្ភពនិងការបំបៅដោះកូនរួមទាំងការមើលថែស្ត្រីដែលមានផលវិបាកទាក់ទងនឹងការបំបៅកូនដោយទឹកដោះម្តាយ និងការផ្សារភ្ជាប់រវាងម្តាយនិងទារក។ ការរួមបញ្ចូលវិធីសាស្ត្រឆ្មបដើម្បីគាំទ្រដល់ក្រុមគ្រួសារដូចបានកំណត់នៅក្នុងសហគមន៍។

### ៣.៥.៤ ចំណេះដឹងនិស្សិត (Knowledge )

នៅចុងបញ្ចប់ម៉ូឌុលទី៤នៃវគ្គ SafeMa អ្នកចូលរួមនឹងអាចធ្វើបានដូចជា៖

- កំណត់និងពិពណ៌នានូវភស្តុតាងស្រាវជ្រាវអំពីអត្ថប្រយោជន៍នៃការបំបៅកូនដោយទឹកដោះនិងអនុសាសន៍របស់អង្គការសុខភាពពិភពលោកក្នុងការបំបៅកូនដោយទឹកដោះម្តាយ
- កំណត់និងពិពណ៌នាអំពីការផ្លាស់ប្តូរសរីរវិទ្យានៃសុដន់អំឡុងពេលមានផ្ទៃពោះនិងក្រោយពេលសម្រាល និងការចាប់ផ្តើមនៃការបំបៅកូនដោយទឹកដោះម្តាយ
- កំណត់និងពណ៌នាអំពីតំរូវការសំរាកនិងអាហាររូបត្ថម្ភដើម្បីទឹកដោះម្តាយ ។
- កំណត់និងពិពណ៌នាទិដ្ឋភាពសង្គមចិត្តសាស្ត្រនិងវប្បធម៌ទាក់ទងបំបៅកូនដោយទឹកដោះម្តាយ
- កំណត់និងពិពណ៌នាតួនាទីរបស់ដៃគូដែលទទួលបានជោគជ័យក្នុងការបំបៅដោះកូននិងការផ្សារភ្ជាប់ជាមួយទារក
- កំណត់និងពិពណ៌នាអំពីសុខភាពមាតានិងទារកក្នុងពេលបំបៅដោះកូន
- កំណត់និងពិពណ៌នាអំពីស្ថានភាពសុខភាពដែលបង្កហានិភ័យពីការបំបៅដោះកូនដោយជោគជ័យសម្រាប់មាតានិងទារក
- កំណត់និងពិពណ៌នាការឆ្លើយតបផ្នែកចិត្តសាស្ត្រចំពោះតួនាទីជាម្តាយក្នុងពេលបន្ថែមទារកទៅក្នុងគ្រួសារ



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

- កំណត់និងពណ៌នាអំពីតំរូវការរបស់បុគ្គលនិងក្រុមគ្រួសារសំរាប់ការរាប់អានគ្នាតាមពេលវេលាខុសគ្នានៅក្នុងវដ្ដជីវិតរៀងៗខ្លួន
- កំណត់និងរៀបរាប់វិធីសាស្ត្រនៃការធ្វើឱ្យអារម្មណ៍មាតា និងការរំពឹងទុកសម្រាប់ខ្លួនឯងទារកនិងគ្រួសារ
- វិភាគទស្សនៈសហគមន៍មូលដ្ឋាននៃការប្រើប្រាស់កន្លែងថែទាំសុខភាពសម្រាប់ការលើកកម្ពស់សុខភាពក្រោយសម្រាល
- កំណត់និងពិពណ៌នាវិធីសាស្ត្រនៃការផ្ដល់ព័ត៌មានដល់បុគ្គលនិងក្រុមគ្រួសារ
- វិភាគតួនាទីរបស់ឆ្មបក្នុងការលើកកម្ពស់សុខភាពក្រោយសម្រាលកូនដែលលើកកម្ពស់ការគោរពភាពស្មោះត្រង់របស់ស្ត្រីខណៈពេលដែលប្រើប្រាស់វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស។

៣.៥.៥ ជំនាញ (Skills )

នៅចុងបញ្ចប់ម៉ូឌុលទី៤នៃវគ្គ SafeMa អ្នកចូលរួមនឹងអាចះ

- លើកកម្ពស់ការបំបៅកូនដោយទឹកដោះដំបូងនិងដោយទឹកដោះម្ដាយសុទ្ធដោយគោរពជម្រើសរបស់ស្ត្រីទាក់ទងនឹងការបំបៅទារកទើបនឹងកើត
- ផ្ដល់ព័ត៌មានអំពីតំរូវការទារក ចំនួនការបៅនិងរយៈពេលនៃការផ្ដល់ចំណីនិងការកើនទំងន់
- ផ្ដល់ការគាំទ្រនិងផ្ដល់ព័ត៌មានអំពីការបំបៅកូនដោយទឹកដោះម្ដាយក្នុងរយៈពេលយ៉ាងតិចប្រាំមួយខែរួមទាំងផ្ដល់ការងារ ការផ្គត់ផ្គង់ទឹកដោះនិងការរក្សាទុកទឹកដោះម្ដាយ។
- កំណត់និងគ្រប់គ្រងបញ្ហាការបំបៅកូនដោយទឹកដោះម្ដាយ (ឧ. ការលាកដោះ ការផ្គត់ផ្គង់ទឹកដោះមិនគ្រប់គ្រាន់ ការយល់ដឹងនៃការឡើងដោះមិនត្រឹមត្រូវ)
- ផ្ដល់ព័ត៌មានដល់ស្ត្រីដែលមានទារកនឹងកើតច្រើន (កូនភ្លោះ)ក្នុងការបំបៅដោះកូន
- គាំទ្រដល់ការបំបៅកូនដោយទឹកដោះនៅក្នុងគ្រួសារនិងសហគមន៍
- ផ្ដល់ព័ត៌មានសុខភាពនិងដំបូន្មានស្ថានភាពស្ត្រីនិងគ្រួសាររបស់ពួកគេម្នាក់ៗ
- ធ្វើការវាយតំលៃយ៉ាងទូលំទូលាយលើតំរូវការសុខភាពគ្រួសារ
- ចូលរួម និងបញ្ជូនស្ត្រីនិងអ្នកដែលគាំទ្រដល់កម្មវិធីបំប៉នបំបៅដោះកូនដោយទឹកដោះម្ដាយ
- បង្ហាញព័ត៌មានអំពីការបំបៅកូនដោយទឹកដោះម្ដាយឱ្យបានត្រឹមត្រូវនិងច្បាស់ហើយឆ្លើយតបទៅនឹងតម្រូវការរបស់បុគ្គលម្នាក់ៗ
- កំណត់តម្រូវការឬបញ្ហាដែលត្រូវការជំនាញបន្ថែមឬការបញ្ជូនបន្តដូចជាផលវិបាកនៃការបំបៅកូនដោយទឹកដោះម្ដាយ
- គ្រប់គ្រងភាពស្មុគស្មាញនៃការបំបៅកូនដោយទឹកដោះម្ដាយនិងបញ្ជូនស្ត្រីនិងទារកដែលត្រូវការថែទាំជំនាញឯកទេស
- ប្រើប្រាស់វិធីសាស្ត្រក្នុងការលើកកម្ពស់សុខភាពក្រោយសម្រាលកូនដែលលើកកម្ពស់ការគោរពភាពស្មោះត្រង់របស់អ្នកជំងឺខណៈពេលដែលប្រើប្រាស់វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស

៣.៥.៦ ប្លង់នៃម៉ូឌុល (Outline of the module)






The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

សូមជ្រាបថាការផ្លាស់ប្តូរអាចនឹងកើតឡើងក្នុងពេលដំណើរការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ម៉ូឌុលនេះ។

៣.៥.៧ គន្លឹះពិចារណា **WP**១.៥ ផែនការឧត្តមភាព (Considerations for WP1.5 Excellency plans

នៅពេលរៀបចំផែនការ WP១.៥ របស់ផែនការឧត្តមភាពស ដៃគូអាស៊ានគួរតែដឹងថាការធ្វើសមាហរណកម្មដោយប្រើ Advanced Mannequin មិនចាំបាច់យកមកប្រើសម្រាប់ការប្រតិបត្តិនៃម៉ូឌុលនេះទេ។ ម៉ានីកាំងសាមញ្ញសម្រាប់បង្ហាញពីទីតាំងនិងបច្ចេកទេសបំបៅកូនដោយទឹកដោះម្តាយ នឹងត្រូវការជាចាំបាច់ក្នុងអំឡុងពេលនៃការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ម៉ូឌុល SafeMa។ អ្នកអប់រំក្នុងតំបន់ត្រូវតែចូលរួមជួយបង្កើតករណីសិក្សាសម្រាប់គ្រួសារ ការលើកកម្ពស់សុខភាពនៅក្នុងសហគមន៍ដែលឆ្លុះបញ្ចាំងពីបរិបទក្នុងតំបន់ ពីព្រោះវាជាការលំបាកសម្រាប់ដៃគូសហគមន៍អឺរ៉ុបក្នុងការចូលរួមធ្វើដោយគ្មានចំណេះដឹងពីបរិបទក្នុងតំបន់នេះ។

៣.៦ ម៉ូឌុលទី៥៖ វិធីសាស្ត្រស្រាវជ្រាវសុខភាព (MODULE 5: Methods in health research )

៣.៦.១ មាតិការ (Content)

ប្រធានបទនេះទាក់ទងនឹងការអភិវឌ្ឍការការស្រាវជ្រាវរួមមានការប្រើប្រាស់ឧបករណ៍ស្រាវជ្រាវ៖ Documented Structured Information Search (DOSIS) ដើម្បីគាំទ្រដល់ការអភិវឌ្ឍជំនាញភាសាអង់គ្លេសបែបសុខភាព ដើម្បីពង្រឹងការស្រាវជ្រាវ។ ការនេះផ្តោតសំខាន់គឺទៅលើការអភិវឌ្ឍ ការគិតពិចារណា និងការបកប្រែការស្រាវជ្រាវអនុវត្តជាក់ស្តែង(១១)។

៣.៦.២ លទ្ធផលនៃការសិក្សា (Learning outcomes)

លទ្ធផលនៃការសិក្សាគឺបានរំពឹងទុក បង្កើនសមត្ថភាព ចំណេះដឹង និងជំនាញ ដែលនិស្សិតសិក្សាក្នុងវគ្គ SafeMa ទទួលបាននៅចុងបញ្ចប់នៃម៉ូឌុល។ ក្នុងអំឡុងពេលនៃការបង្រៀនម៉ូឌុលនីមួយៗ អ្នកអប់រំ SafeMa គួរតែបង្រៀនដោយស្របទៅតាមលទ្ធផលនៃការសិក្សាទាំងនេះ។

៣.៦.៣ សមត្ថភាព(Competencies )

នៅចុងបញ្ចប់ម៉ូឌុលទី៥នៃវគ្គ SafeMa និស្សិតអាចគ្រប់គ្រងការប្រើប្រាស់ឧបករណ៍ UCN DOSIS ខណៈពេលដែលបញ្ចូលការយល់ដឹងអំពីការស្រាវជ្រាវ និងជំនាញភាសាអង់គ្លេសទាក់ទងនឹងសុខភាព។

៣.៦.៤ ចំណេះដឹង (Knowledge )

នៅចុងបញ្ចប់ម៉ូឌុលទី៥នៃវគ្គ SafeMa អ្នកចូលរួមនឹងអាច៖

- កំណត់និងពិពណ៌នាគោលការណ៍នៃការស្រាវជ្រាវនិងការអនុវត្តជាក់ស្តែង
- កំណត់និងពិពណ៌នាគោលការណ៍ក្រមសីលធម៌នៃការអនុវត្តការស្រាវជ្រាវ
- កំណត់និងរៀបរាប់អំពីគោលគំនិតនៃការរាលដាលមេរោគទាក់ទងនឹងសុខភាពមាតានិងទារក
- កំណត់និងពិពណ៌នាអំពីអនុសាសន៍សកលសម្រាប់ការអនុវត្តនិងមូលដ្ឋានភស្តុតាង
- កំណត់និងពិពណ៌នាគោលការណ៍នានានៃឧបករណ៍ DOSIS
- កំណត់និងពិពណ៌នាទ្រឹស្តីទាក់ទងនឹងការគិតត្រិះរិះពិចារណា
- កំណត់និងពិពណ៌នាអំពីសុខភាពនិងការស្រាវជ្រាវពាក្យសព្ទទាក់ទងនឹងអង់គ្លេស
- កំណត់និងរៀបរាប់វិធីសាស្ត្រដើម្បីបកប្រែភស្តុតាងស្រាវជ្រាវទៅជាការអនុវត្តជាក់ស្តែង

៣.៦.៥ ជំនាញ (Skills)

នៅចុងបញ្ចប់ម៉ូឌុលទី៥នៃវគ្គ SafeMa អ្នកចូលរួមនឹងអាចធ្វើបាន៖

- ពិភាក្សាការស្រាវជ្រាវជាមួយស្ត្រីនិងអ្នកជំនាញសុខភាពផ្សេងទៀត



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

- គាំទ្រដល់ការស្រាវជ្រាវផ្នែកឆ្មបដោយចូលរួមក្នុងការស្រាវជ្រាវ
- អនុវត្តវិធីសាស្ត្រសំខាន់ក្នុងការអនុវត្តឆ្មប
- ប្រើវិធីសាស្ត្រដើម្បីបកស្រាយភស្តុតាងស្រាវជ្រាវទៅជាការអនុវត្ត
- ប្រើភាសាអង់គ្លេសដើម្បីសុខភាពនិងការស្រាវជ្រាវជំនាញដែលទាក់ទងការអាននិងយល់ពីវិទ្យាសាស្ត្រ

៣.៦.៦ ប្លង់នៃម៉ូឌុល (Outline of the module )




សូមជ្រាបថាការផ្លាស់ប្តូរអាចនឹងកើតឡើងក្នុងពេលដំណើរការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ម៉ូឌុលនេះ។

៣.៦.៧ គន្លឹះពិចារណា **WP ១.៥** ផែនការឧត្តមភាព (Considerations for WP1.5 Excellency plans)

នៅពេលរៀបចំផែនការ WP ១.៥ របស់គម្រោងសម្រាប់ម៉ូឌុលនេះដៃគូអាស៊ានគួរតែស្វែងរកការស្វែងរកមូលដ្ឋានទិន្នន័យស្រាវជ្រាវដោយឥតគិតថ្លៃក្នុងតំបន់និងបង្កើតថវិកាសម្រាប់ការទិញអត្ថបទស្រាវជ្រាវតែមួយ។
ក្នុងអំឡុងពេលនៃការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ម៉ូឌុល SafeMa អ្នកអប់រំក្នុងតំបន់ត្រូវតែរួបរួមគ្នាដើម្បីអភិវឌ្ឍវគ្គសិក្សាភាសាអង់គ្លេសទាក់ទងនឹងសុខភាពព្រោះនេះជាការពិបាកសម្រាប់ដៃគូសហភាពអឺរ៉ុបក្នុងការផលិតដោយគ្មានចំណេះដឹងនៃបរិបទនិងភាសា។

៣.៧ ម៉ូឌុលទី ៦: ភាពជាគ្រូដឹកនាំកម្មសិក្សាគ្លីនិក (MODULE 6: Clinical preceptorship )

៣.៧.១ មាតិការ (Content)

ប្រធានបទនេះទាក់ទងនឹងការអភិវឌ្ឍជំនាញដើម្បីក្លាយជាឆ្មបអប់រំនៅគ្លីនិក។ ការផ្តោតសំខាន់លើការអនុវត្តនិង ការអភិវឌ្ឍឆ្មបជំនាញអប់រំនៅគ្លីនិក។ ភាពជាអ្នកដឹកនាំដឹកអន្តរកម្មគាំទ្រ និងការប្រាស្រ័យទាក់ទងជាមួយនិស្សិតឆ្មប។

៣.៧.២ លទ្ធផលសិក្សា (Learning outcomes)

លទ្ធផលនៃការសិក្សាគឺបានរំពឹងទុក បង្កើនសមត្ថភាព ចំណេះដឹង និងជំនាញ ដែលនិស្សិត SafeMa គួរតែទទួលបាននៅចុងបញ្ចប់នៃម៉ូឌុលនីមួយៗ។ ក្នុងអំឡុងពេលនៃការបង្រៀនម៉ូឌុលនីមួយៗ អ្នកអប់រំ SafeMa គួរតែបង្រៀនដោយស្របទៅតាមលទ្ធផលនៃការសិក្សាទាំងនេះ។

៣.៧.៣ សមត្ថភាព (Competencies )

នៅចុងបញ្ចប់ម៉ូឌុលទី៦នៃវគ្គ SafeMa និស្សិតនឹងអាចក្លាយជាអ្នកជំនាញក្នុងបរិបទគ្លីនិកមួយដែលរួមបញ្ចូលជាមួយនឹងជំនាញនៃភាពជាអ្នកដឹកនាំនិងសមត្ថភាពក្នុងការធ្វើអន្តរកម្មគាំទ្រជាមួយនិស្សិតឆ្មបនិងអ្នកដទៃទៀត។

៣.៧.៤ ចំណេះដឹង (Knowledge)

នៅចុងបញ្ចប់ម៉ូឌុលទី ៦នៃ SafeMa អ្នកចូលរួមនឹងអាចធ្វើបាន៖

- កំណត់និងពិពណ៌នាតួនាទីឆ្មបជាអ្នកណែនាំកម្មសិក្សាគ្លីនិក អ្នកអប់រំ អ្នកបង្វឹកបង្ហាត់ និងជាគំរូ



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

- កំណត់ និងពិពណ៌នាយុទ្ធសាស្ត្រគាំទ្រដើម្បីត្រួតពិនិត្យអ្នកដទៃ
- កំណត់និងពិពណ៌នាអំពីទ្រឹស្តីទាក់ទងនឹងការធ្វើជាអ្នកអប់រំនៅគ្លីនិក
- កំណត់និងរៀបរាប់អំពីទ្រឹស្តីទាក់ទងនឹងការរៀននៅគ្លីនិក
- វិភាគតួនាទីរបស់ឆ្មបទាក់ទងនឹងវិធីសាស្រ្តបង្រៀនដែលលើកកម្ពស់ការគោរព ភាពសុចរិតរបស់និស្សិត និងការប្រើប្រាស់វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស។

៣.៧.៥ ជំនាញ (Skills)

នៅចុងបញ្ចប់ម៉ូឌុលទី៦នៃវគ្គ SafeMa អ្នកចូលរួមនឹងអាចធ្វើបាន៖

- ទទួលយកតួនាទីឆ្មបជាអ្នកអប់រំ នៅទីកន្លែងគ្លីនិក
- បង្រៀនតាមគ្លីនិកដោយប្រើទ្រឹស្តីដែលពាក់ព័ន្ធ
- ប្រើយុទ្ធសាស្ត្រគាំទ្រដើម្បីត្រួតពិនិត្យអ្នកដទៃ
- ផ្តល់ការត្រួតពិនិត្យដល់និស្សិតឆ្មបដើម្បីធានាថាការអនុវត្តមានភាពត្រឹមត្រូវជាមួយគោលការណ៍ណែនាំ និងការអនុវត្តគ្លីនិកផ្អែកលើភស្តុតាង
- គាំទ្រដល់ការរីកលូតលាស់នៃវិជ្ជាជីវៈតាមរយៈការចូលរួមក្នុងការអប់រំឆ្មបក្នុងតួនាទីជាអ្នកផ្តល់ប្រឹក្សាក្នុងបរិបទគ្លីនិក អ្នកណែនាំ និងជាគំរូនៃការថែទាំ
- ប្រើប្រាស់វិធីសាស្ត្រដើម្បីទទួលបានការព្យាបាលតាមបែបវេជ្ជសាស្ត្រដែលលើកកម្ពស់ការគោរពភាពស្មោះត្រង់របស់អ្នកជំងឺ និងការប្រើប្រាស់វិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស

៣.៧.៦ ប្លង់នៃម៉ូឌុល (Outline of the module)




សូមជ្រាបថាការផ្លាស់ប្តូរអាចនឹងកើតឡើងក្នុងពេលដំណើរការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ម៉ូឌុលនេះ

៣.៧.៧ គន្លឹះពិចារណា **WP ១.៥** ផែនការឧត្តមភាព (Considerations for WP1.5 Excellency plans)

នៅពេលរៀបចំផែនការ WP ១.៥ របស់ផែនការឧត្តមភាពសម្រាប់គម្រោងនេះ ដៃគូអាស៊ានគួរតែប្តេជ្ញាអភិវឌ្ឍសម្ភារៈសិក្សាសម្រាប់ម៉ូឌុលនេះដែលឆ្លុះបញ្ចាំងការអនុវត្តដែលមានស្រាប់របស់ឆ្មបក្នុងបរិបទមូលដ្ឋាន
ព្រោះវាជាការលំបាកសម្រាប់ដៃគូសហគមន៍អឺរ៉ុបក្នុងការចូលរួមធ្វើដោយគ្មានចំណេះដឹងពីបរិបទក្នុងតំបន់។

៣.៨ ម៉ូឌុលទី ៧៖ សិទ្ធិមនុស្ស (MODULE 7: Human rights )

៣.៨.១ មាតិការ (Content)

ប្រធានបទនេះទាក់ទងនឹងការយល់ដឹងនិងការលើកកម្ពស់សិទ្ធិមនុស្សដែលទាក់ទងនឹងការអនុវត្តជំនាញឆ្មបដោយរួមមានចំណេះដឹង សមត្ថភាពស្នូលនៃការអនុវត្តវិជ្ជាជីវៈនៅក្នុងវិសាល



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ភាពក្រមសីលធម៌។ ការផ្តោតសំខាន់គឺទៅលើទស្សនៈវិស័យ ក្រមសីលធម៌ និងការធ្វើសមាហរណកម្មទៅក្នុងការអនុវត្តវិជ្ជាជីវៈគ្លីនិក។

ពី.៨.២ លទ្ធផលសិក្សា (Learning outcomes)

លទ្ធផលនៃការសិក្សាគឺរំពឹងទុក បង្កើនសមត្ថភាព ចំណេះដឹង និងជំនាញ ដែលនិស្សិតសិក្សាក្នុងវគ្គ SafeMa ទទួលបាននៅចុងបញ្ចប់នៃម៉ូឌុល។ ក្នុងអំឡុងពេលនៃការបង្រៀនម៉ូឌុលនេះ អ្នកអប់រំ SafeMa គួរតែបង្រៀនដោយស្របទៅតាមលទ្ធផលនៃការសិក្សាទាំងនេះ។

៣.៨.៣ សមត្ថភាព ( Competencies)

នៅចុងបញ្ចប់ម៉ូឌុលទី៧នៃវគ្គ SafeMa អ្នកចូលរួមនឹងអាចគ្រប់គ្រងការលើកកម្ពស់វិធីសាស្ត្រគ្រឹះលើសិទ្ធិមនុស្ស ចំពោះការអនុវត្តរបស់ឆ្មបដោយរួមបញ្ចូលសមត្ថភាពស្នូលនៃការអនុវត្តវិជ្ជាជីវៈក៏ដូចជាទស្សនៈវិស័យនៃក្រមសីលធម៌។

៣.៨.៤ ចំណេះដឹង ( Knowledge)

នៅចុងបញ្ចប់ម៉ូឌុលទី៧នៃវគ្គ SafeMa អ្នកចូលរួមនឹងអាចៈ

- កំណត់និងពិពណ៌នាគោលគំនិតនៃវិធីសាស្ត្រផ្អែកលើសិទ្ធិមនុស្ស
- កំណត់និងពិពណ៌នាអំពីច្បាប់និងបទបញ្ញានៃយុត្តាធិការទាក់ទងនឹងឆ្មប
- កំណត់និងរៀបរាប់ពីស្តង់ដារសហគមន៍ជាតិ / រដ្ឋ / មូលដ្ឋាននៃការអនុវត្តរបស់ឆ្មប
- កំណត់និងពិពណ៌នាគោលការណ៍សីលធម៌
- កំណត់និងពិពណ៌នាអំពីICM និងទស្សនៈវិជ្ជាឆ្មបដទៃទៀតនៃគុណតម្លៃក្រមសីលធម៌
- កំណត់ និងពិពណ៌នាចំណេះដឹងស្រាវជ្រាវអំពីវប្បធម៌សង្គមអាកប្បកិរិយានិងស្ថានភាពសេដ្ឋកិច្ចដែលតែងតែមានអំពើហឹង្សានិងការរំលោភបំពាន
- កំណត់និងរៀបរាប់អំពីបទដ្ឋានវប្បធម៌និងការអនុវត្តន៍នានាទាក់ទងនឹងការរួមភេទ
- អាពាហ៍ពិពាហ៍ ការបង្កើតកូននិងការចិញ្ចឹមបីបាច់ថែរក្សាកូន
- កំណត់និងពិពណ៌នាទ្រឹស្តីទាក់ទងនឹងគោលការណ៍នៃការផ្តល់អំណាច
- កំណត់និងរៀបរាប់អំពីទ្រឹស្តីទាក់ទងនឹងការរៀនសូត្រនៅគ្លីនិក

៣.៨.៥ ជំនាញ (Skills)

នៅចុងបញ្ចប់ម៉ូឌុលទី៧នៃ SafeMa អ្នកចូលរួមនឹងអាចៈ

- អនុវត្តតាមវិធីសាស្ត្រមូលដ្ឋានសិទ្ធិមនុស្ស
- អនុវត្តទៅតាមគំរូការច្បាប់និងគោលការណ៍សីលធម៌
- ទទួលស្គាល់ការរំលោភច្បាប់បទបញ្ញានិងក្រមសីលធម៌និងចាត់វិធានការសមស្រប
- តស៊ូមតិនិងគាំទ្រស្ត្រីឱ្យក្លាយជាអ្នកធ្វើសេចក្តីសម្រេចចិត្ត ក្នុងការមើលថែពួកគេ
- ផ្តល់ការគាំទ្រសម្រាប់មនុស្សវ័យជំទង់និងជនរងគ្រោះនៃអំពើហឹង្សាប្រឆាំងនឹងភេទរួមទាំងការរំលោភសេពសន្ថវៈ។
- ដឹងអំពីសញ្ញានៃសក្តានុពលនៃការរំលោភបំពានពីរូបរាងកាយឥទ្ធិពលអារម្មណ៍អាកប្បកិរិយាគ្រោះថ្នាក់ដូចជាការប្រើសារធាតុញៀន។
- ស្គាល់ស្ថានភាពដែលត្រូវការជំនាញក្រៅពីការថែទាំរបស់ឆ្មប

៣.៨.៦ ប្លង់នៃម៉ូឌុល (Outline of the module)



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.




សូមជ្រាបថាការផ្លាស់ប្តូរអាចនឹងកើតឡើងក្នុងពេលដំណើរការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ម៉ូឌុលនេះ។

៣.៨.៧ គន្លឹះពិចារណា **WP ១.៥** ផែនការឧត្តមភាព (Considerations for WP1.5 Excellency plans)

ក្នុងអំឡុងពេលនៃការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ម៉ូឌុល SafeMa អ្នកអប់រំក្នុងតំបន់ត្រូវតែរួបរួមគ្នាដើម្បីអភិវឌ្ឍសម្ភារៈទាក់ទងនឹងស្តង់ដារសហគមន៍ជាតិ / រដ្ឋ / សហគមន៍មូលដ្ឋាននៃការអនុវត្តផ្នែកឆ្មបក្នុងតំបន់ ចំណេះដឹងអំពីបរិបទមូលដ្ឋាននិងសមត្ថភាពភាសា។

៣.៩.ម៉ូឌុលទី ៨៖ ការអនុវត្តជាក់ស្តែងនិងការផ្សព្វផ្សាយរបស់ឆ្មប (MODULE 8: Evidence based midwifery)

៣.៩.១ មាតិការ (Content )

ប្រធានបទនេះទាក់ទងនឹងការគាំទ្រវិធីសាស្រ្តប្លែកៗគ្នាក្នុងការអនុវត្តរបស់ឆ្មប និងការថែទាំឆ្មបតាមលក្ខណៈបុគ្គលដោយផ្អែកលើវិធីសាស្រ្តផ្អែកលើជាក់ស្តែង។ ការផ្តោតអារម្មណ៍គឺផ្តោតលើការអភិវឌ្ឍជំនាញសំរេចចិត្តខាងគ្លីនិក ដោយផ្អែកលើការធ្វើសមាហរណកម្មចំណេះដឹងនៃការស្រាវជ្រាវផ្អែកលើជាក់ស្តែងដែលវាល្អបំផុតខាងជំនាញគ្លីនិក។

៣.៩.២ លទ្ធផលសិក្សា (Learning outcomes)

លទ្ធផលនៃការសិក្សាគឺរំពឹងទុក កើនសមត្ថភាព ចំណេះដឹង និងជំនាញ ដែលនិស្សិត SafeMa ទទួលបាននៅចុងបញ្ចប់នៃម៉ូឌុល។ ក្នុងអំឡុងពេលបង្រៀនម៉ូឌុល អ្នកអប់រំក្នុងវគ្គ SafeMa បង្រៀនដោយស្របទៅតាមលទ្ធផលនៃការសិក្សាទាំងនេះ។

៣.៩.៣ សមត្ថភាព (Competencies )

នៅចុងបញ្ចប់ម៉ូឌុលទី៨នៃវគ្គ SafeMa អ្នកចូលរួមនឹងអាចអនុវត្តបានសមត្ថភាពឆ្មបដោយផ្អែកលើការអនុវត្តជាក់ស្តែង។

៣.៩.៤.ចំណេះដឹង (Knowledge)

- កំណត់និងពិពណ៌នាគោលគំនិតនៃការអនុវត្តជាក់ស្តែង
- កំណត់និងពិពណ៌នាអំពីវិធីស្វែងរកបកស្រាយនិងប្រើប្រាស់អក្សរសាស្រ្តស្រាវជ្រាវ
- កំណត់និងពិពណ៌នាអំពីជំនាញគ្លីនិកនិងភាពជាអ្នកដឹកនាំគ្លីនិក
- កំណត់និងពិពណ៌នាវិធីសម្រាប់ចូលរួមរបស់ស្រ្តីក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត
- កំណត់និងរៀបរាប់នូវឧបសគ្គដែលអាចកើតមានសម្រាប់ការធ្វើសមាហរណកម្មប្រកបដោយជោគជ័យនៃការអនុវត្តជាក់ស្តែង។
- កំណត់និងពិពណ៌នាវិធីសាស្រ្តសំខាន់ៗសម្រាប់ធ្វើការសម្រេចចិត្ត

៣.៩.៥. ជំនាញ (Skills)

- អនុវត្តតាមវិធីសាស្រ្តផ្អែកជាក់ស្តែង
- ទទួលស្គាល់នូវឧបសគ្គដើម្បីទទួលបានជោគជ័យដោយការអនុវត្តជាក់ស្តែងនិងខិតខំប្រឹងប្រែងដើម្បីជំនះឧបសគ្គទាំងនេះ



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

- គាំទ្រមតិនិងគាំទ្រស្ត្រីឱ្យក្លាយជាអ្នកធ្វើសេចក្តីសម្រេចចិត្តក្នុងការមើលថែពួកគេ
- អាចធ្វើជាអ្នកជំនាញខាងគ្លីនិកនិងអនុវត្តភាពជាអ្នកដឹកនាំគ្លីនិក
- អាចអាន និងទទួលបានចំណេះដឹងខាងការស្រាវជ្រាវផ្នែកអក្សរសាស្ត្រ។

៣.៩.៦.ប្លង់នៃម៉ូឌុល (Outline of the module)




៣.៩.៧ គន្លឹះពិចារណា **WP** ១.៥ ឧត្តមភាពផែនការ (Considerations for WP1.5 Excellency plans)

ក្នុងអំឡុងពេលនៃការអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់ម៉ូឌុល SafeMa អ្នកអប់រំក្នុងតំបន់ត្រូវតែប្រឹងប្រែងដើម្បីអភិវឌ្ឍសម្ភារៈទាក់ទងនឹងបរិបទក្នុងតំបន់ព្រោះនេះជាការពិបាកសម្រាប់ដៃគូសហភាពអឺរ៉ុបក្នុងការចូលរួមធ្វើដោយមិនដឹងពីបរិបទនៅមូលដ្ឋាននិងការអនុវត្តទាក់ទងនឹងផ្នែកឆ្មបដែលផ្អែកលើភស្តុតាង។

៣.១០ ការចុះកម្មសិក្សាគ្លីនិក (Facilitated internship)

បន្ទាប់ពីសិក្សា១ម៉ូឌុលម្តងៗរហូតដល់៤ម៉ូឌុលនៃវគ្គសិក្សា ការចុះកម្មសិក្សាគ្លីនិករយៈពេល៨សប្តាហ៍នៅកន្លែងគ្លីនិក។ កម្មសិក្សាគ្លីនិកនេះចាំបាច់និស្សិត ចូលរួមដើម្បីទទួលបានលទ្ធផលនៃការសិក្សាទាំង ៤ ម៉ូឌុល និងជានាទូវការបញ្ចប់វគ្គសិក្សា ដើម្បីទទួលបានវិញ្ញាបនបត្រនៃការទទួលស្គាល់។

នៅក្នុង WP ១.២ និង WP ១.៣ បានបញ្ជាក់ច្បាស់អំពីការអនុវត្តទ្រឹស្តីត្រូវបានគេចាត់ទុកថាជាបញ្ហាប្រឈមដ៏សំខាន់មួយនៅក្នុងបណ្តាប្រទេសជាដៃគូ(៣)។ បរិក្ខានិងពេលវេលារៀនមិនគ្រប់គ្រាន់អាចបណ្តាលឱ្យមានឧបសគ្គមួយចំនួនក្នុងការទទួលបានចំណេះដឹងនិងការស្រាវជ្រាវដើម្បីទៅអនុវត្តជាក់ស្តែង។ ក្នុង WP 1.3 លទ្ធភាពនៃការរៀនបានកំណត់នូវការអនុវត្តជាក់ស្តែងត្រូវបានចាត់ទុកថាជាផ្នែកមួយនៃការកែលម្អគុណភាពគួរឱ្យកត់សម្គាល់ដោយដៃគូគម្រោង។

ទស្សនៈវិជ្ជា (Philosophical Approach) និងគោលការណ៍នឹងឆ្លុះបញ្ចាំងផងដែរ (Reflective Practice Learning) អំពីការអនុវត្ត ។ វានឹងជួយទៅលើសមត្ថភាពនិស្សិតដោយផ្សារភ្ជាប់ចំណេះដឹងថ្មីៗពីម៉ូឌុលទៅនឹងការអនុវត្តជាក់ស្តែង។

ដើម្បីគាំទ្រដល់និស្សិតពីការរៀន ទ្រឹស្តីទៅការអនុវត្តកម្មសិក្សាគ្លីនិក និស្សិតត្រូវរៀបចំឯកសារសិក្សាទាក់ទងនូវមុខវិជ្ជា និងស្ថានភាពអនុវត្តគ្លីនិក។ សកម្មភាពការរៀននឹងត្រូវបានកំណត់ពីលទ្ធផលនៃការសិក្សាទាក់ទងនឹងម៉ូឌុលទាំង៤ដែលត្រូវបានសិក្សាចប់មុនពេលចុះកម្មសិក្សាគ្លីនិក។

និស្សិតក៏នឹងត្រូវបំពេញកិច្ចការទាក់ទងនឹងការធ្វើកិច្ចការរៀនផ្សេងៗទៀតដូចជា ការសិក្សាបែបឯករាជ្យ ការធ្វើការជាក្រុម ឬការបង្រៀនដោយគ្រូកម្មសិក្សាគ្លី និក។



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

គ្រប់ស្ថានភាពគ្លីនិក
សកម្មភាពរៀនសូត្រនិងការចាត់តាំងទាំងអស់នឹងទាក់ទងទៅនឹងខ្លឹមសារនៃវិធីសាស្ត្រនៃការបង្រៀននិងលទ្ធផលនៃការសិក្សាទាំង ៨ ម៉ូឌុលនៃវគ្គសិក្សា SafeMa ។

ឧត្តមភាពគម្រោង (WP ១.៥) ដៃគូរទាំងអស់កំណត់ការអនុវត្តគម្រោងត្រូវបានរំពឹងថានឹងចូលរួមចំណែកក្នុងការអភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់ផលប៉ះពាល់នៅពេលអនុវត្ត (១) ។ យុទ្ធសាស្ត្រទាំងនេះគួរតែផ្អែកលើគោលការណ៍គ្រឹះពី WP ១.៤។ ចំណុចខាងក្រោមគួរត្រូវបានរួមបញ្ចូលនៅក្នុងកម្មសិក្សាគ្លីនិកអន្តរវាសិក ដើម្បីផ្សារភ្ជាប់គម្លាតនៃការអនុវត្តទ្រឹស្តី៖

- ផែនការនិងការរៀបចំអប់រំក្នុងកម្មសិក្សាគ្លីនិកក្នុងកម្មសិក្សាគ្លីនិកអន្តរវាសិកគួរតែគោលដៅដើម្បីគាំទ្រលទ្ធផលនៃការសិក្សាទាំង ៨ ម៉ូឌុល។
- ឧបករណ៍សិក្សា (learning tools) ស្ថានភាពសិក្សា និងគ្រូដឹកនាំណែកម្មសិក្សាគ្លីនិកចាំបាច់ផ្ទេរបង្ហាញពីទ្រឹស្តីទៅការអនុវត្តគ្លីនិក គួរតែត្រូវបានផ្តល់អតិភាពនិងច្បាស់។
- ដៃគូរអនុវត្តគម្រោងគួរពិពណ៌នា និងកំណត់ជាក់ច្បាស់និងពេលវេលាកម្មសិក្សាគ្លីនិក ។ នៅក្នុងគម្រោង វគ្គសិក្សា SafeMa ជាមូលដ្ឋានគំរូនៃការឆ្លុះបញ្ចាំងនិងកិច្ចការសិក្សាសាលាបានដាក់ឲ្យធ្វើ។
- គំនិតគួរតែត្រូវបានដាក់បញ្ចូលដើម្បីគាំទ្រសមត្ថភាពរបស់និស្សិត ពេលវេលា និងបន្ទប់សម្រាប់អនុវត្តវាស់ចំណេះដឹងរបស់សិស្ស។ ការវាស់ចំណេះដឹងនេះគឺសំដៅទៅលើការបង្ហាញដែលនិស្សិតត្រូវគិតពិចារណា និងពិនិត្យមើលសកម្មភាព អារម្មណ៍និងឥរិយាបថដែលទាក់ទងនឹងបទពិសោធន៍នៃការអនុវត្តគ្លីនិកដែលនិស្សិតបានទទួលការយល់ដឹងថ្មីៗ។ តាមវិធីនេះ អាចចូលរួមចំណែកដល់និស្សិតផ្ទាល់ក៏ដូចជាដំណើរការនៃការរៀន។ និស្សិតបញ្ជាក់ពីចំណេះដឹងដោយអាចរៀបចំជា៖

- កាអនុវត្តប្រចាំថ្ងៃដោយមានការណែនាំ ជាមួយគ្រូណែនាំកម្មសិក្សាគ្លីនិក
- ការបញ្ជាក់ដោយសកម្មភាពសរសេ
- ការបញ្ជាក់ដោយការប្រជុំរវាងនិស្សិតនិងនិស្សិត និស្សិតជាមួយគ្រូណែនាំ
- ការបញ្ជាក់ដោយក្រុមនិស្សិត គ្មានគ្រូណែនាំកម្មសិក្សាគ្លីនិក

គ្រូណែនាំកម្មសិក្សាគ្លីនិកគួរតែដឹងអំពីសារៈសំខាន់នៃការបញ្ជាក់អំពីរៀនអនុវត្តតាមនិងគាំទ្រដើម្បីឲ្យសិស្សចូលរួមបញ្ជាក់ពីចំណេះដឹងអនុវត្តជាក់ស្តែងទៅវិញទៅមក (Circle of Reflection) ការបកប្រែជាភាសាអង់គ្លេសដោយពួកយើងនិងបានបង្ហាញក្នុងរូបភាពទី ២ ខាងក្រោម។




រូបភាពទី២៖ ឧទាហ ... របស់យើង) (១២)



The European Commiss ... dorsement of the contents, which reflect the views c ... which may be made of the information contained tl

ដើម្បីគាំទ្រដល់និស្សិតក្នុងការសម្រេចបាននូវវត្ថុបំណងនៃការសិក្សាទាក់ទង វគ្គសិក្សារបស់ SafeMa ធនធានគួរតែត្រូវបានដាក់ចូលទៅក្នុងដំណើរការតាមដានការសិក្សារបស់និស្សិត និងពង្រឹងនិស្សិតនៅពេលចាំបាច់។
ការធ្វើបែបនេះអាចធ្វើទៅបានដោយមានការសន្ទនាដែលបានកំណត់ទុក ជាមួយនិស្សិតគ្រប់រូបក្នុងអំឡុងពេលកម្មសិក្សាគ្លីនិក។

ការគ្រោងសន្ទនាដែលបាន កំណត់ទុកអាចត្រូវបានធ្វើឡើងតាមមាតិកាដូចខាងក្រោមដើម្បីគោរពតាមវត្ថុបំណងដែលបានរៀបរាប់ខាងលើ។

- នៅពេលចាប់ផ្តើមកម្មសិក្សាអន្តេវាសិក៖ សូមបញ្ជាក់ តើនិស្សិតនោះជានរណា អ្វីដែលនិស្សិតដឹងនិងមានចំណេះដឹងរួចហើយ តើនិស្សិតរៀនអ្វីប្រសើជាងគេ
- នៅពាក់កណ្តាលនៃកម្មសិក្សាគ្លីនិកអន្តេវាសិក៖ បង្កើតការសង្ខេបចំណេះដឹងនៃនិស្សិតអំពីកម្មសិក្សានេះ និងរបៀបអភិវឌ្ឍខ្លួន និងការអភិវឌ្ឍន៍វិជ្ជាជីវៈដើម្បីចេញទៅបំរើការងារ ។
- នៅចុងបញ្ចប់នៃកម្មសិក្សាគ្លីនិកអន្តេវាសិក៖ បង្កើតចំណាប់អារម្មណ៍ទូទៅមួយអំពីរបៀបដែលនិស្សិតទទួលបានចំណេះដឹងក្នុងពេលចុះកម្មសិក្សាគ្លីនិកអន្តេវាសិក។

### ៣.១០.១ គន្លឹះពិចារណា **WP** ១.៥ សម្រាប់ផែនការឧត្តមភាព (Considerations for WP1.5 Excellency plans)

សមាសធាតុនៃកម្មសិក្សាគ្លីនិកខាងលើ ត្រូវយកមកគិតពិចារណាដោយរួមបញ្ចូលពីបរិបទក្នុងតំបន់នៅពេលដែលដៃគូអាស៊ានបង្កើតរបាយការណ៍ឧត្តមភាព។

គេមិនអាចបញ្ជាក់ទាំងអស់អំពីបរិបទតាមកន្លែងកម្មសិក្សាគ្លីនិកអន្តេវាសិក និង បែបបទការណែនាំ និងគ្រូណែនាំកម្មសិក្សាគ្លីនិកទេ ហើយដៃគូអាស៊ានគួរតែធ្វើការពិភាក្សាជាមួយមន្ទីរពេទ្យក្នុងតំបន់និងមន្ទីរពេទ្យឯកជនដើម្បីគាំទ្រដល់កិច្ចសហការដ៏ជិតស្និទ្ធក្នុងការសម្របសម្រួលកម្មសិក្សាគ្លីនិកអន្តេវាសិក។
ដូច្នេះវាចាំបាច់ណាស់សម្រាប់ដៃគូអាស៊ានធ្វើការវិភាគឲ្យបានដិតដល់នូវចំនុចដែលបានណែនាំនៅក្នុងកម្មសិក្សាគ្លីនិកក្នុងវគ្គ SafeMa និងបែបបទការ អនុវត្តវានៅតាមទីកន្លែង។ ការកែសំរួលឧបករណ៍សម្រាប់ដំណើរសិក្សាឬបែបបទគឺជាចាំបាច់។

## ៤. ជំពូកទី ២ ការស្រាវជ្រាវ SafeMa (Chapter 2 Safema Research)

ក្នុងជំពូក ការស្រាវជ្រាវ SafeMa ត្រូវបានបង្ហាញ។ គោលគំនិតនៃការសរសេរព័ត៌មាន (Information Literacy) នៅក្នុងបរិបទ SafeMa ត្រូវបានបង្ហាញ ដូចក្នុងគោលគំនិតនៃ evidence-based practice ។

### ៤.១ ការសរសេរព័ត៌មាន (Information Literacy)

នៅក្នុងរបាយការណ៍ដែលបានផ្សព្វផ្សាយរួចហើយ ឧត្តមភាពសិក្សានិងការស្រាវជ្រាវនៅក្នុងការអប់រំឆ្មប (Academic and Research Excellence in midwifery ed cation and research) *និង* ការយល់ដឹងពីការស្រាវជ្រាវត្រូវបានគេចាត់ទុកថាជាធាតុមួយដ៏សំខាន់ក្នុងការគាំទ្រដល់ការអនុវត្តឆ្មបដែលផ្អែកលើភស្តុតាង(WP ១.១) ។
គោលបំណងនៃការធ្វើបែបនេះគឺដើម្បីពង្រឹងសមត្ថភាពនិស្សិតនិងអ្នកអនុវត្តដើម្បីកំណត់គំនិតផ្សេងៗដែលចាំបាច់ដើម្បីស្រាវជ្រាវនិងស៊ើបអង្កេតក្នុងការអនុវត្តផ្ទាល់ ក៏ដូចជាពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការស្វែងរកអាននិងការយល់ដឹងពីភាពខ្លាំងនិងភាពខ្សោយនៃអក្សរសិល្ប៍ដែលបានបោះពុម្ពផ្សាយហើយ និងធ្វើឱ្យលទ្ធផលនៃការស្រាវជ្រាវទាំងនោះមាននៅក្នុងការអនុវត្តប្រចាំថ្ងៃ (WP ១.១) ។


The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ដើម្បីសង្កេតមើលអំពីការយល់ដឹងពីការស្រាវជ្រាវ
និស្សិតនិងអ្នកអនុវត្តត្រូវតែចូលរួមក្នុងដំណើរការនៃការទទួលនិងប្រើប្រាស់ចំណេះដឹងដែលកំពុងកើត
ឡើង ដើម្បីធ្វើឱ្យការយល់ដឹងស្រាវជ្រាវកាន់តែស៊ីជម្រៅជាងមុន (WP ១.១) ។
ដំណើរការបង្ហាញឲ្យឃើញពីឧត្តមភាពនៃឆ្មបដែលធ្វើការក្នុងការអនុវត្តគ្លីនិកបន្ទាប់ពីបញ្ចប់ការសិក្សា
ដោយត្រូវទទួលបានការគាំទ្រក្នុងការបណ្តុះបណ្តាលនៃគម្រោង
ការអភិវឌ្ឍជំនាញក្នុងការយល់ដឹងអំពីការស្រាវជ្រាវ
ក៏ដូចជាការលើកទឹកចិត្តដើម្បីគាំទ្រដល់វិធីសាស្ត្រនៃការអនុវត្តដែលផ្អែកលើភស្តុតាងជាមួយនឹងសមត្ថ
ភាពថ្មីដែលពួកគេទទួលបាន។

៤.២ ការរៀបចំប្រតិបត្តិ (The setting of implementation)

នៅក្នុងដំណាក់កាលរៀបចំផ្សព្វផ្សាយរបាយការណ៍វិភាគ(WP១.២) វាត្រូវបានកំណត់អត្តសញ្ញាណ
អត្ថបទស្រាវជ្រាវ(literature review)
នៅតែជាបញ្ហាប្រឈមដ៏គួរឱ្យកត់សម្គាល់ក្នុងចំណោមឆ្មបនៅក្នុងបណ្តាប្រទេសដៃគូអាស៊ាន
ដែលបានសបង្ហាញភាពខ្វះខាតរបស់ឆ្មបមិនបានប្រើប្រាស់លទ្ធផលចេញពីការស្រាវជ្រាវ។
ជាញឹកញាយធ្វើឲ្យឆ្មបពឹងផ្អែកលើគោលការណ៍ណែនាំ "ក្រៅផ្លូវការ"
និងការអនុវត្តគ្លីនិកដែលមានលក្ខណៈធម្មតា របស់ពួកគេ (WP ១.២) ។

ការយល់ដឹងទាំងនេះត្រូវបានគាំទ្រដោយលទ្ធផលនៃរបាយការណ៍នៃការវិភាគគម្លាត (gap analysis report) ដែលបង្ហាញពីកង្វះខាតចំណេះដឹងពីការស្រាវជ្រាវ
កង្វះខាតចំណេះដឹងទាក់ទងនឹងការអនុវត្តផ្អែកលើភស្តុតាង ក៏ដូចជាពុំសូវប្រើប្រាស់កុំព្យូទ័
ជំនាញការអានអង់គ្លេស ក្នុងបរិបទប្រទេសវៀតណាម។ការអនុវត្តក៏ជាឧបសគ្គ និង
ការយល់ដឹងពីការស្រាវជ្រាវ ការរៀនពេញមួយជីវិត
និងការអនុលោមតាមការអនុវត្តផ្អែកលើភស្តុតាងក៏ត្រូវបានរកឃើញនៅក្នុងប្រទេសកម្ពុជាផងដែរ
(WP១.២) ។

ទស្សនៈវិស័យដូចគ្នានេះក៏ត្រូវបានបំភ្លឺតាមរយៈការពិភាក្សានិងការងារជាក្រុមក្នុងចំណោម
ដៃគូរទាំងអស់នៃគម្រោង SafeMa
ដែលបានអនុវត្តក្នុងអំឡុងពេលទស្សនៈកិច្ចសិក្សាទាំងនៅក្នុងប្រទេសក្រិកនិងដាណឺម៉ាក។
ក្នុងដំណើរទស្សនៈកិច្ចសិក្សានេះ
វាបានបំភ្លឺយ៉ាងច្បាស់ដៃគូរអន្តរជាតិក្នុងប្រទេសវៀតណាមនិងប្រទេសកម្ពុជាដែលបានរកឃើញពីការប
ញ្ចូលគ្នាទាំង ៨ម៉ូឌុល ក្នុងវគ្គសិក្សា SafeMa ។ នេះមិនត្រឹមតែពង្រឹងការអប់រំឆ្មបប៉ុណ្ណោះទេ
តែថែមទាំងជួយគាំទ្រដល់ការអនុវត្តគ្លីនិកនៅតាមបណ្តាប្រទេសរៀងៗខ្លួនផងដែរ។
ការចាប់អារម្មណ៍និងបង្ហាញទាក់ទងនឹងការបំពេញបន្ថែមក្នុងការធ្វើលំហាត់
វិធីសាស្ត្របង្រៀននិងធនធានសំរាប់ការបង្រៀន និងសមត្ថភាពនិស្សិតទទួលបានកើតចេញ
ការស្រាវជ្រាវនិងការបញ្ចូលគ្នានេះ ។

ដៃគូរក៏រំលឹកឡើងវិញពីតម្រូវការដើម្បីពង្រឹងការអនុវត្តជាក់ស្តែងនិងការផ្សព្វផ្សាយរបស់ឆ្មប
និង បានលើកឡើង
ថាការអនុវត្តនិងរបកគំហើញថ្មីអាចអូសបន្លាយ។អង្គការក្រៅរដ្ឋាភិបាលក្នុងតំបន់នឹងដើរតួនាទីយ៉ាងសំ
ខាន់ក្នុងធ្វើការស្រាវជ្រាវថ្មី។ ទោះបីជាមានបញ្ហាទាក់ទងនឹងភាពខ្សោយក្នុងការស្រាវជ្រាវ
គួបផ្សំនឹងជំនាញអានអង់គ្លេសមិនល្អនិងការអនុវត្តមូលដ្ឋានជាក់ស្តែង (WP ១.២)
ដៃគូបានបង្ហាញថាពួកគេចង់ចូលរួមវិភាគទានដើម្បីរកភ័ស្តុតាងដែលពាក់ព័ន្ធនិងគាំទ្រដល់សមត្ថភាព
ឆ្មបក្នុងការឆ្លុះបញ្ចាំងចំណេះដឹងដែលចាំបាច់ក្នុងការស្រាវជ្រាវ និងរៀនដើម្បីបានអនុវត្តផ្ទាល់។

៤.៣ គោលការណ៍និងសារៈសំខាន់នៃការគាំទ្រការអនុវត្តជាក់ស្តែងនិងការផ្សព្វផ្សាយ

(Principles and importance of supporting an Evidence Based Practice )

ដូចដែលបានលើកឡើងនៅក្នុងរបាយការណ៍ឧត្តមភាពសិក្សានិងស្រាវជ្រាវនៅក្នុងការអប់រំនិង
ការស្រាវជ្រាវឆ្មប (*Academic and Research Excellence in midwifery education and research)* (WP ១.១)



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

លោក David Sackett et al´s បានកំណត់និយមន័យ evidence-based practice approach ទាក់ទងនឹងនិយាមស្តង់ដាសម្រាប់ឧត្តមភាពថែទាំគុណភាពក្នុងផ្នែកថែទាំសុខភាព។ evidence-based practice តម្រូវឲ្យដំណើរការចំណេះដឹង ការស្រាវជ្រាវជាក់ស្តែង ។ អ្នកអនុវត្តគ្លីនិកនិងគុណតម្លៃព្រមទាំងកាលៈទេសៈរបស់អ្នកជំងឺ ត្រូវបានដាក់បញ្ចូល ដើម្បីធ្វើការសម្រេចចិត្តថែទាំអ្នកជំងឺម្នាក់ៗ(WP១.១)។

ក្នុងដំណើរទស្សនកិច្ចសិក្សា SafeMa វាច្បាស់ណាស់ថាមានភាពខុសគ្នាយ៉ាងខ្លាំងនៅក្នុងតួនាទីនិងស្វ័យភាពរបស់ឆ្មបដែលមាននៅក្នុងប្រទេសទាំងពីរក៏ដូចជានៅក្នុងតំបន់របស់ប្រទេសនីមួយៗ។ វាអាចនាំឱ្យមានការប្រែប្រួលដ៏ធំនៃវិធីដែលឆ្មបប្រើប្រាស់ក្នុងការអនុវត្តជំនាញគ្លីនិករបស់នាងដែលត្រូវបានគេកំណត់ថាជាសមត្ថភាពប្រកបដោយវិជ្ជាជីវៈរបស់គ្រូពេទ្យក្នុងការប្រើប្រាស់ជំនាញគ្លីនិក និងបទពិសោធន៍របស់ពួកគេដើម្បីកំណត់ពីស្ថានភាពសុខភាពរបស់អ្នកជំងឺបានយ៉ាងឆាប់រហ័ស (WP ១.១) ។ លើសពីនេះទៀតដៃគូបានបង្ហាញចំណាប់អារម្មណ៍យ៉ាងខ្លាំងទៅលើជំនាញក្នុងការផ្តល់ការយកចិត្តទុកដាក់ដល់ស្ត្រីនិងគ្រួសារច្រើនជាងនៅក្នុងការអនុវត្តផ្ទាល់របស់ពួកគេ។ ពួកគេបានចាត់ទុករឿងនេះថាសមស្របនឹងនិយាមអន្តរជាតិនិងសីលធម៌។ ដៃគូបានរាយការណ៍ថាកិច្ចខិតខំប្រឹងប្រែងដ៏អស្ចារ្យត្រូវបានធ្វើឡើងនៅក្នុងប្រទេសទាំងពីរដើម្បីធានាឱ្យមានការយល់ព្រមជាព័ត៌មានសម្រាប់ស្ត្រីក្នុងការអនុវត្តជាក់ស្តែង។ ទោះយ៉ាងណាក៏ដោយពួកគេមានបទពិសោធតិចក្នុងការស្វែងរក ការយល់ដឹងឲ្យកាន់តែស៊ីជម្រៅអំពីជីវិត តម្លៃ និងបទពិសោធន៍របស់ស្ត្រី។ ដើម្បីគាំទ្រដល់ការធ្វើសមាហរណកម្មគុណតម្លៃរបស់អ្នកជំងឺដែលត្រូវបានកំណត់ថាជាជម្រើសរបស់ស្ត្រីក្នុងការប្រឹក្សានិងការរំពឹងទុកក្នុងពេលជួបជាមួយអ្នកជំនាញគ្លីនិក ក៏ដូចជាកាលៈទេសៈរបស់នាងក្នុងស្ថានភាពគ្លីនិក និងស្ថានភាពគ្លីនិកអន្តរជាតិ (WP ១.១) ទៅក្នុងការសម្រេចចិត្តសម្រាប់ការថែទាំអ្នកជំងឺម្នាក់ៗ។ វាពិតជាសំខាន់ណាស់ដែលពួកគេត្រូវទទួលស្គាល់ថាវាជាធាតុសំខាន់មួយនៃការអនុវត្តដោយផ្អែកលើភស្តុតាង។

ការពង្រឹងពីការយល់ដឹងអំពីការស្រាវជ្រាវ និងការចាត់ទុកវាជាផ្នែកមួយនៃម៉ូឌុលនៃវគ្គសិក្សា SafeMa អាចគាំទ្រវាល់ធាតុទាំងអស់នៃមូលដ្ឋានគ្រឹះនៃការធ្វើកោសល្យវិច័យភស្តុតាងនិងវិជ្ជាជីវៈឆ្មបនៃប្រទេសដៃគូនៃប្រទេសកម្ពុជានិងវៀតណាម។ ដូច្នេះធាតុទាំងបី; ភស្តុតាងស្រាវជ្រាវល្អបំផុតសម្រាប់ជំនាញគ្លីនិក របស់អ្នកអនុវត្តនិងគុណតម្លៃរបស់អ្នកជំងឺធ្វើការប្រកបដោយភាពសុខដុម។ លើសពីនេះទៀតការយល់ដឹងអំពីការស្រាវជ្រាវសមត្ថភាពក្នុងការរៀនសូត្រពេញមួយជីវិតនិងការឆ្លុះបញ្ចាំងពីការអនុវត្តផ្ទាល់ខ្លួនគឺស្ថិតក្នុងចំណោមការរួមបញ្ចូលគ្នាដ៏សំខាន់នៃជំនាញនិងលក្ខណៈដែលចាំបាច់សម្រាប់ឆ្មបក្នុងការអនុវត្តថ្នាំដែលមានភស្តុតាងនិងអនុវត្តតាមតំរូវការរបស់អ្នកជំងឺម្នាក់ៗ (WP ១.១) ។

## ៤.៤ គោលដៅនិងការយល់ដឹងអំពីទម្រង់ព័ត៌មានដើម្បីគាំទ្រដល់ការយល់ដឹងអំពីការស្រាវជ្រាវ (Goals and understandings of the Information Competency Profile to support research awareness)

ពត៌មានអំពីសមត្ថភាពរបស់ UCN ជាការព័ណ៌នាអំពីសមត្ថភាពទូទៅសម្រាប់និស្សិតយកទៅអនុវត្ត (១៣) ។

គោលបំណងនៃទម្រង់នេះគឺដើម្បីឱ្យនិស្សិតទទួលបានសមត្ថភាពដែលទាក់ទងនឹងចំណេះដឹងតម្រង់ទិសប្រកបដោយវិជ្ជាជីវៈ ដែលវានឹងលើកទឹកចិត្តនិងគាំទ្រនិស្សិតឱ្យក្លាយជាអ្នកអនុវត្តបែបឆ្លុះបញ្ចាំង (Reflective Practitioner)។ ការនេះគួរតែជួយដល់ការយកចិត្តទុកដាក់របស់និស្សិតទាក់ទងនឹងការអនុវត្តជាក់ស្តែង និងការលើកកម្ពស់ក្នុងការអនុវត្តវិជ្ជាជីវៈនិងដោយផ្អែកលើជាក់ស្តែង។



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ទម្រង់សមត្ថភាពព័ត៌មានមានធាតុបីដែលត្រូវបានបង្ហាញក្នុងរូបភាពទី ៣ (១៣)
រូបភាពទី ៣៖ ឧទាហរណ៍អំពីធាតុផ្សំសំខាន់ៗនៃសមត្ថភាពព័ត៌មាន (ការបកប្រែរបស់យើង) (១៣)




ព័ត៌មាននេះគាំទ្រដល់គំនិតក្នុងរបាយការណ៍ដល់ការសិក្សានិងឧត្តមភាពស្រាវជ្រាវរបស់ឆ្មបក្នុងការអប់និងការស្រាវជ្រាវ (WP.១.១) ព្រោះវាផ្តោតលើសមត្ថភាពសិស្សក្នុងការស្រាវជ្រាវជាក់ស្តែង ការស្វែងយល់ និងការរិះរកលើការស្រាវជ្រាវ។សមត្ថភាពទាំងអស់នេះត្រូវបានគាំទ្រ និងបង្កើនសមត្ថភាពការអប់រំឆ្មប ដើម្បីផ្តល់ទំនុកចិត្តដល់ឆ្មបក្នុងការអានពីការស្រាវជ្រាវ (WP ១.១) ។

៤.៥ ការប្រមូលការស្រាវជ្រាវ (Collection of research)

ព័ត៌មានរបស់ UCN ដែលបានបង្ហាញនៅក្នុងកថាខណ្ឌចុងក្រោយ គាំទ្រដល់ការអភិវឌ្ឍរបស់និស្សិតក្លាយជាអ្នកអនុវត្ត (Reflective Practitioner)។ ធាតុសំខាន់មួយនៅក្នុងព័ត៌មានស្រាវជ្រាវគឺប៉ិនប្រសបដើម្បីស្រាវជ្រាវចំណេះដឹងថ្មីៗដែលបានពីការប្រមូលរបកគំហើញថ្មី។ បញ្ហាប្រឈមនៃបរិបទ SafeMa ការបង្ហាញ UCN DOSIS tool សម្រាប់ការស្វែងរកព័ត៌មាន។

ក្នុងអំឡុងពេលនៃការប្រៀបធៀបទិន្នន័យ WP១.២ ការវិភាគ និងការអង្កេតទិន្នន័យ ពី WP១.៣ ស្តីពីទស្សនៈកិច្ចសិក្សានៅដាណឺម៉ាកនិងអាតែន បានបង្ហាញយ៉ាងច្បាស់ពីបញ្ហាប្រឈមជាច្រើននៅក្នុងបរិបទពីដៃគូអាស៊ានដែលអាចរារាំងដល់គម្រោង SafeMa ។និស្សិតអភិវឌ្ឍសម្រាប់ការមូលព័ត៌មានពីការស្រាវជ្រាវ។

យើងបានសន្និដ្ឋានថាបញ្ហាប្រឈមធំៗពីព័ត៌មានស្រាវជ្រាវ នៅក្នុងបរិបទដូចខាងក្រោម៖

- ជំនាញភាសាអង់គ្លេសមិនល្អ
- កង្វះលទ្ធភាពក្នុងការទទួលបានព័ត៌មានទាក់ទងនឹងទិន្នន័យស្រាវជ្រាវតាមអ៊ីនធឺណិត
- កង្វះខាតឧបករណ៍ដើម្បីអនុវត្តការសិក្សាស្រាវជ្រាវដើម្បីស្វែងរកព័ត៌មាន

ក្នុងដំណើរទស្សនកិច្ចសិក្សានៅដាណឺម៉ាក
ដៃគូអាស៊ានបានបង្ហាញពីតម្រូវការក្នុងការលើកកម្ពស់ជំនាញភាសាអង់គ្លេសរបស់ឆ្មបទាក់ទងនឹងសុខភាពក្នុងបរិបទតំបន់ដើម្បីអាចឱ្យពួកគេអភិវឌ្ឍសមត្ថភាពក្នុងការយល់ដឹងពីការស្រាវជ្រាវ។
ដូច្នេះអ្នកអប់រំ SafeMa ត្រូវតែបញ្ចូលវគ្គសិក្សាភាសាអង់គ្លេសទាក់ទងសុខភាពនៅក្នុងម៉ូឌុលទី៥នៃវគ្គ SafeMa ដែលស្របទៅនឹងបរិបទនិងតម្រូវការតំបន់។



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ដៃគូអាស៊ានត្រូវការជាចាំបាច់ដើម្បីអភិវឌ្ឍវគ្គសិក្សាភាសាអង់គ្លេសដែលទាក់ទងសុខភាពក្នុងតំបន់នេះ ព្រោះវាទាមទារចំណេះដឹងអំពីបរិបទនិងភាសាក្នុងតំបន់។

ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចសិក្សានៅដាណឺម៉ាក ដៃគូអាស៊ានបានបង្ហាញពីតម្រូវការក្នុងការទទួលបាននូវទិន្នន័យស្រាវជ្រាវ ព្រោះថាវានៅមានកំរិតក្នុងការទទួលបាននូវទិន្នន័យស្រាវជ្រាវតាមអ៊ិនធឺណែតនៅបរិបទតំបន់នៅតាមស្ថាប័នអប់រំជាន់ខ្ពស់។ ដោយ សារការស្វែងរកព័ត៌មានទាមទារការចំណាយខ្ពស់ យើងចង់សំណូមពរឱ្យបង្កើតការចូលប្រើមូលដ្ឋានទិន្នន័យដោយឥតគិតថ្លៃ ប៉ុន្តែការចំណាយថវិកាសម្រាប់ទិញអត្ថបទស្រាវជ្រាវនីមួយៗក៏អាចបង្កើតឡើងផងដែរ។ ថវិកាសម្រាប់ការទិញអត្ថបទស្រាវជ្រាវតែមួយមុខនេះគួរតែត្រូវយកមកពិចារណានៅពេលដៃគូអាស៊ីកំពុងរៀបចំគម្រោងឧត្តមភាព WP ១.៥។

ក្នុងអំឡុងពេលទស្សនៈកិច្ចសិក្សានៅប្រទេសដាណឺម៉ាក ដៃគូអាស៊ានបានបង្ហាញពីតម្រូវការសម្រាប់និស្សិត SafeMa ក្នុងការទទួលបានជំនាញដើម្បីប្រើប្រាស់ឧបករណ៍សម្រាប់ស្វែងរកព័ត៌មានស្រាវជ្រាវ។ ឧបករណ៍ UCN DOSIS ដែលត្រូវបានបង្កើតឡើងដោយ បណ្ណាល័យ UCN បានផ្តល់នូវឧបករណ៍ដ៏សាមញ្ញមួយសម្រាប់ស្វែងរកព័ត៌មានតាម DOSIS ដោយវាជាអក្សរកាត់នៃឃ្លា **DO**cumented **S**ystematic **I**nformation **S**earch (១១) ។




រូបភាពទី ៤៖ រូបភាពបង្ហាញពីធាតុសំខាន់ៗនៃឧបករណ៍ UCN DOSIS (ការបកប្រែរបស់យើង) (១១)

ឧបករណ៍ UCN DOSIS នឹងក្លាយជាឧបករណ៍ដ៏សំខាន់មួយនៅក្នុងម៉ូឌុលទី៥នៃវគ្គ SafeMa ព្រោះវាអាចជួយអោយនិស្សិត SafeMa ធ្វើការស្រាវជ្រាវព័ត៌មានដែលមានលក្ខណៈជាប្រព័ន្ធដែលត្រូវបានកំណត់គោលដៅ



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

និងត្រូវបានបង្កើតឡើងយ៉ាងល្អទាក់ទងនឹងប្រធានបទដែលបានជ្រើសរើស និងធ្វើអោយប្រសើរឡើងនូវព័ត៌មានស្រាវជ្រាវ រចនាសម្ពន្ធ និងស្វែងរកយ៉ាងល្អទាក់ទងកំណត់ប្រធានបទ និងធ្វើឲ្យប្រសើឡើងនូវការស្រាវជ្រាវរបស់និស្សិតនិងការគាំទ្រការអនុវត្តផ្ទាល់របស់ឆ្មប (១១) ។

## ៤.៦ គន្លឹះពិចារណាសម្រាប់ **WP ១.៥** ផែនការឧត្តមភាព (Considerations for WP1.5 Excellency plans)

ដៃគូទាំងអស់របស់ SafeMa ត្រូវតែប្តេជ្ញាចិត្តក្នុងការធ្វើសមាហរណកម្មនិងគាំទ្រដល់គោលគំនិតនៃការអនុវត្តជាក់ស្តែងរបស់ឆ្មបក្នុងដំណាក់កាលទាំងអស់នៃការធ្វើផែនការនិងការប្រតិបត្តិនៃគម្រោង SafeMa ។ លើសពីនេះទៀតវាចាំបាច់ត្រូវផ្តោតលើវិធីដែលពាក់ព័ន្ធនឹងការអភិវឌ្ឍលើការស្រាវជ្រាវព័ត៌មាន។

ការពិចារណាទាក់ទងនឹងបញ្ហានេះគួរតែជាផ្នែកមួយនៃគម្រោងWP១.៥សម្រាប់ឧត្តមភាព។

# ៥. ជំពូកទី ៣ ការណែនាំអំពីវិជ្ជាជីវៈ (Chapter 3 Career guidance)

វិសាលភាពនៃជំពូកនេះគឺបង្ហាញពីគ្រោងសម្រាប់ការណែនាំវិជ្ជាជីវៈនៅក្នុងវគ្គសិក្សា SafeMa ។ ជំពូកនេះមានការណែនាំខ្លីៗទៅលើគោលការណ៍ទូទៅវិជ្ជាជីវៈ និងអនុសាសន៍ចំពោះវិធីដែលនិស្សិតគួរតែអនុវត្តនៅក្នុងវគ្គសិក្សា SafeMa ជាពិសេសលើការណែនាំវិជ្ជាជីវៈសម្រាប់ជនជាតិភាគតិចនិងប្រជាជននៅតំបន់ជនបទ។

## ៥.១ ការណែនាំវិជ្ជាជីវៈក្នុង **SafeMa** (SafeMa career guidance)

អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ (OECD) កំណត់ណែនាំវិជ្ជាជីវៈ "ជាសេវាកម្មនិងសកម្មភាពដែលមានគោលបំណងដើម្បីជួយដល់មនុស្សគ្រប់វ័យនិងគ្រប់ចំណុចទាំងអស់ក្នុងជីវិត។ពួកគេធ្វើការអប់រំ ការបណ្តុះបណ្តាលនិងជម្រើសវិជ្ជាជីវៈ និងការគ្រប់គ្រងអាជីពរបស់ពួកគេ" ។ (១៤)

សកម្មភាពណែនាំការងារនេះត្រូវបានចែកជា ៥ ជំនាញដោយយោងទៅតាមការិយាល័យការងារអន្តរជាតិ International Labor Office (ILO): ព័ត៌មានពីអាជីព ការអប់រំពីអាជីព ការប្រឹក្សាពីអាជីព ការប្រឹក្សាពីការងារ និងកន្លែងធ្វើការងារ។ តាមការផ្តល់អនុសាសន៍ពីសេវាកម្មអាជីពក្នុងវគ្គសិក្សា SafeMa ដែលគួរតែផ្តល់ជូននៅក្នុងចំណុចទាំង៥យ៉ាងនេះ (១៤) ។

### ៥.១.១ ព័ត៌មានអាជីព (Career information)

មណ្ឌល SafeMa (SafeMa Hub) គួរផ្តល់សេវាកម្មដល់និស្សិត ដែលបានចុះឈ្មោះចូលរៀនឲ្យទទួលបាននូវព័ត៌មានគ្រប់គ្រាន់ដើម្បីរៀបចំផែនការនិងរក្សាការងារក្នុងកំឡុងនិងក្រោយពេលបញ្ចប់ការសិក្សា។ ទាំងនេះរួមបញ្ចូលទាំងព័ត៌មានអំពីការចុះឈ្មោះចូលរៀនវគ្គសិក្សា SafeMa អាជីពឱកាសក្នុងរៀន ទីផ្សារការងារ និងឱកាសការងារបន្ទាប់ពីបញ្ចប់ការសិក្សា។

ដូចការវិភាគរបស់ WP ១.២ នៃបរិបទក្នុងតំបន់បានបង្ហាញថានិស្សិត SafeMa នាពេលអនាគតអាចនឹងមានជំនាញឆ្មបចម្រុះ រាប់ចាប់ពីការបណ្តុះបណ្តាលដើមវគ្គសិក្សា រហូតដល់បញ្ចប់ទទួលវិញ្ញាបនបត្រ ឆ្មប។ ដូច្នេះចាំបាច់ណាស់និស្សិតនៅពេលបញ្ចប់វគ្គសិក្សាគួរតែទទួលបាននូវសេវាកម្មព័ត៌មានពីអាជីពនិងឱកាសសម្រាប់កម្មវិធី“taster” ដែលអនុញ្ញាតឱ្យពួកគេធ្វើការជ្រើសរើសវគ្គសិក្សាមុនពេលធ្វើការសម្រេចចិត្ត។ ឧទាហរណ៍ កម្មវិធី“taster” អាចដាក់បញ្ចូលទៅក្នុង MOOC របស់ម៉ូឌុល SafeMa មុនពេលនិស្សិតធ្វើការសំរេចចិត្តក្នុងការចុះឈ្មោះចូលរៀន។

ការយកចិត្តទុកដាក់ខ្ពស់ក្នុងការផ្សព្វផ្សាយនៅតាមទីជនបទដើម្បីធានាបាននូវឱកាសស្មើគ្នាក្នុងការចូលរួមវគ្គសិក្សា SafeMa ដោយមិនគិតពីទីកន្លែងរស់នៅនិងជនជាតិ។ គោលដៅសំខាន់គឺដើម្បីផ្តល់លទ្ធភាព និងផ្តល់សិទ្ធដល់បុគ្គលដើម្បីបើកចំហរ ឬមិនការគៀបសង្កត់មិនគឺតពី ភេទ ពូជសាសន៍ វណ្ណៈ សាសនា ឬពិការភាព។

### ៥.១.២ ការអប់រំអាជីព (Career education)



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

វគ្គសិក្សា SafeMa គួរតែផ្តល់ឲ្យមានសេវាកម្ម ផ្តល់ប្រឹក្សាណែនាំដែលសិស្សអាចទទួលបាននូវការប្រឹក្សាយោបល់ក្នុងកំឡុងពេលសិក្សា និងស្វែងយល់ពីគោលបំណងគុណតម្លៃនិងរបៀបដែលពួកគេអាចចូលរួមចំណែកដល់សង្គម។ វាផ្តល់ឱ្យពួកគេនូវចំណេះដឹងអំពីទីផ្សារការងារ ជំនាញក្នុងការអប់រំជីវិតនិងជម្រើសការងារ និងធ្វើផែនការអាជីព។

អ្នកប្រឹក្សាយោបល់គួរតែផ្តោតសំខាន់លើបញ្ហាប្រឈមដល់និស្សិតជនជាតិភាគតិច និងនិស្សិតមកពីតំបន់ជនបទជួបប្រទះ ដូចជាការរើសអើង ការទទួលបានឱកាសមិនស្មើគ្នា និងការលំបាកក្នុងការចូលរួមវគ្គសិក្សា SafeMa ដោយសារតែការរស់នៅក្នុងតំបន់ជនបទដែលធ្វើឲ្យមានការលំបាកក្នុងការធ្វើដំណើរ និងការលំបាកក្នុងការប្រើប្រាស់អ៊ីនធឺណិត។ ល។

## ៥.១.៣ ការប្រឹក្សាយោបល់អាជីព (Career counseling)

មណ្ឌល SafeMa (SafeMa Hub) គួរតែផ្តល់សេវាកម្មដើម្បីជួយនិស្សិតឱ្យយល់ដឹងពីគោលដៅ និងសេចក្តីប្រាថ្នារបស់ពួកគេដើម្បីស្វែងយល់ពីអត្តសញ្ញាណវិជ្ជាជីវៈផ្ទាល់ខ្លួន ការផ្តល់ព័ត៌មាន ការប្តេជ្ញាចិត្តក្នុងការរៀន និងការគ្រប់គ្រងការផ្លាស់ប្តូរអាជីពដោយបានគិតទុកមុននិងមិនបានគ្រោងទុកមុន។

## ៥.១.៤ ការប្រឹក្សាការងារ (Employment counseling)

វគ្គសិក្សា SafeMa គួរតែផ្តល់សេវាកម្មឱ្យនិស្សិតដឹងពីគោលបំណងនៃការធ្វើការងារភ្លាមៗ ការយល់និងដំណើរការនៃការងារនិងឱកាសបណ្តុះបណ្តាលជំនាញបន្ថែមទៀត និងសិក្សាអំពីជំនាញដើម្បីស្វែងរកនិងរក្សាការងារដូចជា ការសរសេរCV ឬរៀនពីរបៀបនៃការសម្ភាសអំពីជំនាញ។

## ៥.១.៥ ការរកការងារធ្វើ (Job placement )

វគ្គសិក្សា SafeMa គួរតែផ្តល់ជូននូវសេវាកម្មរៀបចំឲ្យនិស្សិតស្វែងរកការងារដែលផ្តោតជាពិសេសលើការផ្តល់ឱកាសស្មើគ្នា សម្រាប់ជនជាតិភាគតិចនិងនិស្សិតដែលរស់នៅក្នុងតំបន់ជនបទ។

## ៥.២ គន្លឹះពិចារណាសម្រាប់ **WP** ១.៥ (Key Considerations for WP 1.5)

ដៃគូទាំងអស់របស់ SafeMa ត្រូវតែប្តេជ្ញាបញ្ចូលផែនការទាក់ទងនឹងការធ្វើការណែនាំពីអាជីពដល់និស្សិត ទៅក្នុងគម្រោង WP១.៥ ។

# ៦. ជំពូកទី ៤ ចីរភាពគម្រោង (Chapter 4 Project sustainability)

វិសាលភាពនៃជំពូកនេះគឺបង្ហាញនៅដំណាក់កាលនេះ (ដំណាក់កាលទី១ នៃគម្រោង) គោលគំនិតនិរន្តរភាព “តាមរយៈការរចនាឡើង” ពោលគឺត្រូវបង្កើតគោលការណ៍ណែនាំនិងសម្ភារបណ្តុះបណ្តាល និងវគ្គសិក្សាដើម្បីផ្តល់សិទ្ធដល់ដៃគូក្នុងការធានាបាននូវលទ្ធភាពដើម្បីសម្រេចលទ្ធផលគម្រោងនិងនៅតែបន្តលទ្ធផលនេះទៀតបន្ទាប់ពីគម្រោងត្រូវបានបញ្ចប់ក៏ដោយ។

វាត្រូវបានផលិតឡើងដោយផ្អែកលើព័ត៌មាន (Literature Review) ដែលទាក់ទងនឹងការអនុវត្តប្រកបដោយភាពជោគជ័យនៃគំរោង Erasmus+ ហើយក៏ជាលទ្ធផលនៃសិក្ខាសាលាដែលមានការចូលរួមពីសមាជិកទាំងអស់នៃបេសកម្មមកពីប្រទេសវៀតណាមនិងប្រទេសកម្ពុជាដែលបានចូលរួមក្នុងដំណើរទស្សនកិច្ចសិក្សានៅទីក្រុងអាតែន។

**សារសំខាន់ទី ១៖** ការរៃអង្គាសប្រាក់និងការកសាងភាពជាដៃគូដ៏រឹងមាំនៅគ្រប់កម្រិតទាំងអស់គឺមានសារៈសំខាន់បំផុតដើម្បីបង្កើតយន្តការក្នុងការផ្តល់យោបល់ត្រឡប់ជាបន្តជាមួយអង្គការដែលកំពុងធ្វើការនិងធានានូវនិរន្តរភាពគម្រោង។

**សារសំខាន់ទី ២៖** សមាជិកនិងបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលនៅក្នុងគម្រោងនឹងធានាថា



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ជំនាញដែលទទួលបាននឹងត្រូវប្រើប្រាស់បន្ទាប់ពីគម្រោងនេះត្រូវបានបញ្ចប់។ ដូច្នេះពួកគេគឺជាធនធានមនុស្សដែលធានាបាននូវការបន្ត និងការឲ្យតម្លៃបន្ថែមទៅលើគម្រោង។

**សារសំខាន់ទី ៣៖** ប្រព័ន្ធផ្សព្វផ្សាយបែបឌីជីថលនិងបណ្តាញសង្គមមានសក្តានុពលក្នុងការធានាមិនត្រឹមតែការផ្សព្វផ្សាយពីគម្រោងប៉ុណ្ណោះទេ វាថែមទាំងជាឧបករណ៍ដ៏មានឥទ្ធិពលសម្រាប់ការកសាងភាពសាមគ្គីភាពក្នុងសង្គម។

**សារសំខាន់ទី ៤៖** ការបន្តនិងនិរន្តរភាពរបស់គម្រោងនឹងត្រូវពឹងផ្អែកយ៉ាងខ្លាំងទៅលើវិធីដែលអ្នកពាក់ព័ន្ធប្រើប្រាស់ធនធាននិងព័ត៌មានដែលទទួលបាន ក្នុងការអភិវឌ្ឍន៍គម្រោង។

គម្រោងទាំងមូលត្រូវបានរចនាឡើងតាមរបៀបមួយដើម្បីធានាថាសមិទ្ធផលរបស់វាគឺជាឧបករណ៍អប់រំដែលអាចប្រើបាន ដោយភាពងាយស្រួល និងមិនគិតថ្លៃ។ វានឹងទទួលបានការគាំទ្រពីការធ្វើសកម្មភាពដែលទាក់ទាញចំណាប់អារម្មណ៍ និងការលើកកំពស់ពីការយល់ដឹងទាក់ទងនឹងតម្លៃបន្ថែមរបស់វា ដោយក្នុងនោះមានដូចជា វគ្គសិក្សា SafeMa និង MOOC, មជ្ឈមណ្ឌល SafeMa, ខ្សែបណ្តាញ, ការស្រាវជ្រាវនិងរង្វាន់និងឧត្តមភាពក្នុងការផ្សព្វផ្សាយពីផ្នែកឆ្មបក៏ដូចជាសន្និសិទអន្តរជាតិនៅចុងបញ្ចប់នៃគំរោង។ ដោយពិចារណាថាគោលដៅយុទ្ធសាស្ត្រនៃគម្រោងគឺដើម្បីក្លាយជាគំរូនៃឧត្តមភាពក្នុងការលើកកម្ពស់ការអប់រំផ្នែកឆ្មបដែលមានគុណភាពនៅអាស៊ីអាគ្នេយ៍ និងលើសពីនេះវាច្បាស់ណាស់ថាវាផ្តោតលើវិជ្ជាជីវៈផ្នែកឆ្មបនិងសុខភាពបន្តពូជគ្រប់ប្រភេទហើយមិនត្រូវបានកំណត់ចំពោះតែនិស្សិតឡើយ។ ពោលគឺអ្នកជំនាញថែទាំសុខភាពដែលធ្វើការក្នុងវិស័យសាធារណៈនិងឯកជន ស្ថាប័នសិក្សា សមាគមកម្មករ អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ។ ដូច្នេះការបណ្តុះបណ្តាលជាក់លាក់មួយត្រូវបានគេរៀបចំទុកជាមុនសម្រាប់បុគ្គលិករដ្ឋបាលដើម្បីធានាបាននូវការងារនិងការរែអង្គាសប្រាក់ (មិនទាក់ទងនឹងភាពស្ថិតស្ថេរ) ។ ការបណ្តុះបណ្តាលនឹងត្រូវបានអនុវត្តជាផ្នែកមួយនៃផែនការនិរន្តរភាព។ សិក្ខាសាលានឹងត្រូវបានបញ្ជូនតាមរយៈ SafeMa VLE (នេះនឹងផ្តល់នូវការសាកល្បងសម្រាប់ SafeMa VLE) ។ ឯកសារបណ្តុះបណ្តាលនឹងអាចអនុវត្តជាក់ស្តែងនិងបើកចំហរដល់ VLE សម្រាប់បុគ្គលិកជំនាញផ្សព្វផ្សាយដើម្បីប្រើប្រាស់ពេញនិងក្រោយពេលផ្តល់ជូនគម្រោង។ ដៃគូដែលមានទំនួលខុសត្រូវគឺ UHS ។ ផែនការសកម្មភាពដែលបានស្នើដែលនឹងជាមូលដ្ឋាននៃការបណ្តុះបណ្តាលរួមមានដូចខាងក្រោម៖

- ដើម្បីធានាថាសកម្មភាព គម្រោង និងលទ្ធផលអាចដឹងលឺដល់ជនទូទៅឲ្យបានច្រើនដែលអាចធ្វើទៅបាន សំណើរនេះគឺដើម្បីធ្វើការបណ្តុះបណ្តាលអំពីវិធីផ្តួចផ្តើម និងថែរក្សាតាមរយៈពេលនៃគម្រោងការទំនាក់ទំនង និងការសន្ទនាគ្នាដោយខ្ជាប់ខ្ជួនជាមួយអ្នកពាក់ព័ន្ធក្នុងតំបន់ដើម្បីពង្រឹងទំនាក់ទំនងដែលមានស្រាប់ ដូចជាវិទ្យាស្ថាន ស្ថាប័នវិជ្ជាជីវៈ អាជ្ញាធរសាធារណៈ ជំនាញថែទាំសុខភាព អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ។ ក្នុងវគ្គបណ្តុះបណ្តាលកម្រិតអឺរ៉ុបស្តីពីវិធីរុករកបណ្តាញទំនាក់ទំនងនិងបណ្តាញសហគមន៍អឺរ៉ុបផ្តល់ជូនដើម្បីឱ្យមានទំនាក់ទំនងជាមួយគម្រោងនិងមានគំនិតផ្តួចផ្តើមស្រដៀងគ្នា។
- ដើម្បីពង្រឹងអាំងតង់ស៊ីតេនិងការពង្រីកកិច្ចសហប្រតិបត្តិការក្នុងចំណោមអ្នកចូលរួម
- ការបណ្តុះបណ្តាលអំពីវិធីដើម្បីកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធនិងបណ្តាញដែលពួកគេចូលរួមដើម្បីផ្សព្វផ្សាយលទ្ធផល
- ការបណ្តុះបណ្តាលអំពីរបៀបបង្កើតនិងស្វែងរកបញ្ជីឈ្មោះអ្នកពាក់ព័ន្ធជាមួយបណ្តាញសហគមន៍អឺរ៉ុបដើម្បីយល់ដឹងពីសកម្មភាពដែលពាក់ព័ន្ធនឹងការកេងប្រវ័ញ្ច។



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ការវិភាគលម្អិតនៃនិរន្តរភាពរបស់គម្រោងរួមទាំងការផ្តល់អនុសាសន៍នឹងត្រូវបានព្រាងនៅក្នុងដំណាក់កាលចុងក្រោយនៃគម្រោង។ វានឹងរួមបញ្ចូលទាំងការមើលឃើញក្នុងមួយផ្នែកខាងក្រោម៖

•និរន្តរភាពផ្នែកហិរញ្ញវត្ថុ

•ចីរភាពរបស់អង្គការ

•និរន្តរភាពនៃប្រតិបត្តិការ

ការគណនាលទ្ធផលនៃគម្រោងដៃគូដែលមានទំនួលខុសត្រូវនឹងក្លាយជា NKUA ដែលនឹងបង្កើតទំរង់នៃមគ្គុទេសក៍ដោយផ្អែកលើសិក្ខាសាលាស្តីពីការកសាងសមត្ថភាពលើបណ្តាញ និងការរៃអង្គាសប្រាក់ដែលនឹងត្រូវប្រគល់ជូនបុគ្គលិករដ្ឋបាលនៃប្រទេសដៃគូ។ វានឹងផ្តល់នូវការណែនាំជាក់ស្តែងក្នុងលក្ខណៈបត់បែននិងគោលដៅស្តីពីវិធីកសាងការរួបរួមគ្នាយូរអង្វែងនិងរៃអង្គាសថវិកាសម្រាប់សមត្ថភាពទ្រទ្រង់គម្រោង។

## ៦.១ គន្លឹះពិចារណាសម្រាប់ **WP** ១.៥ (Key Considerations for WP 1.5)

ការវិភាគលម្អិតនៃនិរន្តរភាពរបស់គម្រោងរួមទាំងការផ្តល់អនុសាសន៍នឹងត្រូវបានព្រាងនៅក្នុងដំណាក់កាលក្រោយនៃគម្រោង។ដៃគូសហភាពអ៊ឺរ៉ុប NKUAទទួលខុសត្រូវចំពោះកិច្ចការនេះ។

ការបណ្តុះបណ្តាលជាក់លាក់មួយត្រូវត្រៀមទុកសម្រាប់បុគ្គលិករដ្ឋបាលដើម្បីធានាបាននូវបណ្តាញនិងការរៃអង្គាសប្រាក់។ ការបណ្តុះបណ្តាលនឹងត្រូវបានអនុវត្តជាផ្នែកមួយនៃផែនការនិរន្តរភាព។ ដៃគូដែលទទួលខុសត្រូវចំពោះកិច្ចការនេះគឺUHSយោងតាមការពិពណ៌នាក្នុងគម្រោង។ UHS គួរតែរួមបញ្ចូលផែនការសម្រាប់ការបណ្តុះបណ្តាលជាក់លាក់នេះនៅក្នុងផែនការរបស់ពួកគេសម្រាប់ឧត្តមភាព WP១.៥ ។

## ៦.២ សេចក្តីសង្ខេបប្រតិបត្តិ (Executive summary)

របាយការណ៍គំរូ SafeMa សម្រាប់ឧត្តមភាពឆ្មបនេះបង្កើតបានជាផ្នែកសំខាន់មួយនៃគម្រោង SafeMa ព្រោះវាមានគោលបំណងបង្ហាញនិយាមច្បាស់លាស់សម្រាប់វគ្គសិក្សា SafeMa ដែលនឹងត្រូវបង្កើតឡើងនៅក្នុងបណ្តាប្រទេសជាដៃគូអាស៊ី។

របាយការណ៍នេះបានគូសបញ្ជាក់ថាដៃគូទាំងអស់របស់ SafeMa ត្រូវតែប្តេជ្ញាចិត្តក្នុងការធ្វើសមាហរណកម្មនិងគាំទ្រវិធីសាស្រ្តដែលផ្អែកលើសិទ្ធិមនុស្សនៅគ្រប់ដំណាក់កាលនៃការធ្វើផែនការនិងការប្រតិបត្តិនៃគម្រោង SafeMa ។

របាយការណ៍នេះបង្ហាញពីទស្សនវិជ្ជាទូទៅនៃវគ្គសិក្សា SafeMa ដែលត្រូវបានបំផុសគំនិតដោយទស្សនវិជ្ជានៃការអនុវត្តតាមបែបឆ្លុះបញ្ចាំង ពីព្រោះវិធីសាស្រ្តនេះនឹងជួយណែនាំក្នុងការអភិវឌ្ឍកម្មវិធី SafeMa WP២ ។

របាយការណ៍បង្ហាញពីឧបករណ៍អប់រំសម្រាប់គ្រូនិងសិស្សដែលត្រូវការដើម្បីគាំទ្រដល់ការលើកកម្ពស់ការអនុវត្តការឆ្លុះបញ្ចាំង។

ម៉ូឌុលទាំង ៨ របស់ SafeMa ត្រូវបានបង្ហាញជាមួយនឹងលទ្ធផលនៃការសិក្សាដែលមានរយៈពេល ៤ សប្តាហ៍ក្នុងម៉ូឌុលនីមួយៗ។ ម៉ូឌុលទាំង ៨ របស់ SafeMa រួមមាន MOOC អមដោយការបង្រៀន ការបណ្តុះបណ្តាលក្រុមការងារជំនាញ ការចាត់តាំង ការធ្វើតេស្ត និងការប្រឡង។

### ៦.២.១ ចំណងជើងសម្រាប់ម៉ូឌុលទាំង ៨ (Headlines for the 8 modules)

• ម៉ូឌុលទី១៖ការធ្វើឲ្យប្រសើឡើងជំនាញគ្លីនិកឆ្មប-ការលើកកម្ពស់ឲ្យមានការឈឺពោះសម្រាលកូនធម្មតា

• ម៉ូឌុលទី២៖ការអនុវត្តជំនាញគ្លីនិកកម្រិតខ្ពស់ ឆ្មបទី២ - ការតាមដានគភ៌និងសុវត្ថិភាពម្តាយ

• ម៉ូឌុលទី ៣៖ ការអនុវត្តគ្លីនិកកម្រិតខ្ពស់ ឆ្មបទី ៣ ការសង្គ្រោះបន្ទាន់ម្តាយនិងទារក

•ម៉ូឌុលទី៤ ៖ការលើកកម្ពស់សុខភាពក្រោយសម្រាលក្នុងការគ្រប់គ្រងរបស់ឆ្មប

• ម៉ូឌុលទី ៥៖ វិធីសាស្រ្តស្រាវជ្រាវសុខភាព

•ម៉ូឌុលទី ៦៖ ភាពជាគ្រូដឹកនាំកម្មសិក្សាគ្លីនិក

•ម៉ូឌុលទី ៧៖ សិទ្ធិមនុស្ស

•ម៉ូឌុលទី ៨៖ ការអនុវត្តជាក់ស្តែងនិងការផ្សព្វផ្សាយរបស់ឆ្មប

បន្ទាប់ពីស៊េរីនីមួយៗនៃម៉ូឌុល ៤ វគ្គនៃការចុះកម្មសិក្សាគ្លីនិកដែលមានរយៈពេល ៨ សប្តាហ៍នឹងត្រូវអនុវត្ត។
កម្មសិក្សាទាំងនេះចាំបាច់ត្រូវសម្របសម្រួលសម្រាប់អ្នកចូលរួមវគ្គសិក្សាដើម្បីគាំទ្រដល់លទ្ធផលនៃការសិ



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

ក្សាជាច្រើនទាក់ទងនឹងវគ្គសិក្សាទាំង ៨ និងជានានូវការបញ្ចប់វគ្គសិក្សាដើម្បីទទួលបានសញ្ញាប័ត្រនិងវិញ្ញាបនប័ត្រនៃការទទួលស្គាល់។

របាយការណ៍នេះរាប់បញ្ចូលនូវអនុសាសន៍នៅក្នុងកថាខណ្ឌទាំងអស់សម្រាប់អ្វីដែលគួរតែត្រូវបានពិចារណានិងរួមបញ្ចូលនៅពេលដៃគូអាស៊ីបង្កើតផែនការសម្រាប់ឧត្តមភាពរបស់ពួកគេនៅក្នុងផែនការ WP១.៥សម្រាប់ឧត្តមភាព។ នេះរួមបញ្ចូលទាំងអនុសាសន៍សម្រាប់ការលើកកម្ពស់ការស្រាវជ្រាវលើការអភិវឌ្ឍសេវាកម្ម និង មជ្ឈមណ្ឌល SafeMa សម្រាប់ការណែនាំពីអាជីព និងនិរន្តរភាពនៃគម្រោង។



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

## ៧. ឯកសារយោង (References)


1. Detailed description of the project. An Erasmus+ collaboration supported by European Union. Educations Hubs for Excellence in Midwifery/SafeMa. Version 1, 2018
2. Thisted MH, Cajus G, Jepsen I. An Erasmus+ collaboration supported by European Union; Academic and Research Excellence in midwifery education and research. SafeMa, WP1, Task 1.1. Version 1, 2019
3. Puchner K, Manousaki A. An Erasmus+ collaboration supported by European Union; Gap Analysis Report. SafeMa, WP1, Task 1.2. Version 1, 2019
4. World Health Organization. *WHO recommendations: Intrapartum Care for a positive Childbirth Experience. Geneva*, 2018. Licence: CC BY-NC-SA 3.0 IGO. [cited 2020 Feb 4]. Available from: *https://www.who.int/reproductivehealth/publications/intrapartum-care-guidelines/en/*
5. Walsh D. Evidence and skills for Normal Labour and Birth - A guide for Midwives. Second Edition. New York, 2012
6. Straus SE, Glaziou P, Richardson WS, Haynes RB, Pattani R, Veroniki AA Evidence- Based Medicine – How to practice and teach EBM. Fifth Edition. Oxford, 2019
7. Horn LH, Jensen CG, Kjærsgaard T, et al. Hvidbog om Refleksiv Praksislæring: En læringstilgang for professionshøjskoler og erhvervsakademier [Institutional document]. Aalborg: Professionshøjskolen UCN, Programmet for Refleksiv Praksislæring; 2019. p. 21
8. Hiim H, Hippe E. Undervisningsplanlægning for faglærere. 3. udgave. Hans Reitzel, 2018
9. Frey N, Everlove S, Fisher D. Productive Group Work: How to Engage Students, Build Teamwork, and Promote Understanding. Virginia, 2009
10. International Confederation of Midwives. Essential competencies for midwifery practice- 2018 Update. 2019
11. University College North of Jutland. DOSIS guide. [Institutional document] [Internet]. Aalborg: UCN; 2019 [cited 2020 Feb 4]. Available from: https://www.ucnbib.dk/da/node/874
12. Bjerknes MS, Bjørk IT. Praktiske studier – perspektiver på refleksjon og læring. Tano,1997
13. Westerkam H, Mortensen KR, Hansen LE, et al. En fælles informationskompetenceprofil for studerende ved de sundhedsfaglige professionsbacheloruddannelser, UCN [Institutional document] [Internet]. Aalborg: UCN; 2019. 7 p. [cited 2020 Feb 4]. Available from: https://www.ucviden.dk/portal/files/64472527/Informationskompetenceprofil_maj2019.pdf




The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.

14. Hansen E. International Labour Office. Career Guidance- A resource Handbook for Low- and Middle-income Countries. Geneva, 2006



The European Commission's support for the production of this publication does not constitute an endorsement of the contents, which reflect the views only of the authors, and the Commission cannot be held responsible for any use which may be made of the information contained therein.